**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ
# (ករណីខេត្តព្រៃវែង)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.មឹន ច័ន្ទកេសី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់**បរិញ្ញាបត្រ**

ជំនាញ**នីតិសាស្ត្រ** ជំនាន់ទី១៤

ឆ្នាំចូលសិក្សា ២០០៩

ឆ្នាំសរសេរសារណា២០១៤

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ:

- លោកឪពុក **មឺន ប៊ុន្នា**
- អ្នកម្តាយ **ខឹម ភូឡាប**

គឺជាអ្នកមានគុណដែលបានផ្តល់កំណើតដល់រូបខ្ញុំ ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តី ហើយបានផ្តល់ការទូន្មានប្រកបដោយព្រហ្មវិហារធម៌ល្អប្រពៃ និង ពលិកម្មគ្រប់បែបយ៉ាងដល់កូនអោយទទួលបានជោគជ័យគ្រប់ការងារ ពិសេសក្នុងការសិក្សា តាំងពីបឋមរហូតដល់បានបញ្ចប់ថ្នាក់មហាវិទ្យាល័យ។ ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះ បងស្រីបង្កើតតែមួយគត់របស់នាងខ្ញុំដែលបានផ្តល់ថវិកា និង ជួយលើកកម្លាំងចិត្តដល់រូបនាងខ្ញុំ ព្រមទាំងទទួលយកនូវដំបូន្មានរបស់លោក ឪពុក អ្នកម្តាយ បានធ្វើអោយគ្រួសាររបស់យើងមានកិត្តិយសល្អរហូតដល់សព្វថ្ងៃ។

- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- លោក **ទេព សូរ៉ែន** និង លោក **ឃិត សូខួច** ជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- លោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានបង្កនូវលក្ខណៈងាយស្រួល ដល់ការសិក្សា ជួយបង្ហាត់បង្រៀន ពន្យល់ណែនាំអស់ពីសមត្ថភាព និង ដាស់តឿន អប់រំគ្រប់បែបយ៉ាងក្នុងពេលសិក្សាកន្លងមក។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ:

- លោក **នៃ សុផល** នាយកដ្ឋានមន្ទីរសុរិយោដីខេត្តព្រៃវែង
- លោក **ហាប់ ផល្លី** សាស្ត្រាចារ្យដែលបានជួយពន្យល់ណែនាំ ក្នុងការចុះធ្វើការស្រាវជ្រាវដោយចង្អុលបង្ហាញផ្លូវក្នុងការធ្វើសារណានេះ ប្រព្រឹត្តទៅដល់ទីបញ្ចប់ប្រកបដោយជោគជ័យ និង ពោរពេញទៅដោយអត្ថន័យ និង មានខ្លឹមសារ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ:

- លោក **ម៉ន សាមី** អនុប្រធានមន្ទីរសុរិយោដីខេត្តព្រៃវែង
- លោកស្រី **ស៊ាន យុន្នី** អនុប្រធានមន្ទីរទទួលបន្ទុកការងារសុរិយោដី និង ភូមិសាស្ត្រ
- លោក **ហេង ឃួរ** មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យខេត្តព្រៃវែង និង មន្ត្រីអនុវត្តកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីខេត្តព្រៃវែង ដែលបានផ្តល់កន្លែងអោយចុះសិក្សាស្រាវជ្រាវ និងផ្តល់ព័តមានយ៉ាងក្បោះក្បាយដល់រូបនាងខ្ញុំ។

# អារម្ភកថា

សារណាមួយនេះ គឺជាស្នាដៃតូចមួយដែលកកើតឡើងពីការស្វែងរកស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ ជាពិសេសគឺវាផុសចេញពីការព្យាយាមយ៉ាងស្វិតស្វាញ និងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ ចិត្ត ដើម្បីបង្កើតនូវសារណាមួយនេះឡើង ទុកជាទ្រព្យសម្បត្តិផ្នែកចំណេះដឹង ចំណេះធ្វើ និងទុកជាភស្តុតាងប្រចាំសមត្ថភាព ចេះដឹងទៅលើ ការសិក្សាផ្នែកនីតិសាស្ត្រ ។

នាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយឥតឧបមា ដោយសារនាងខ្ញុំទទួល បានចំណេះសមត្ថភាព បន្ថែមថ្មីៗ ប្លែកៗជាច្រើន កាន់តែប្រសើរជាងនេះទៅទៀតនោះ ពាក់ព័ន្ធនឹងចម្ងល់ មួយចំនួនដែលទាក់ទងនឹងការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធទាំងក្នុងករណីខេត្តព្រៃវែង និងក្នុងទូទាំងប្រទេសកម្ពុជាទាំងមូលក៏ដោយក្តី គឺត្រូវបានបើកទូលាយរាល់ការ បកស្រាយកាន់តែច្បាស់ពីមួយថ្ងៃទៅមួយថ្ងៃទៅតាមអ្វីដែលនាងខ្ញុំបានធ្វើការស្រាវជ្រាវ។ ជាមួយគ្នានេះផងដែរ សារណានេះនឹងបង្ហាញនូវគន្លឹះដ៏ល្អប្រសើរ ថាត្រូវធ្វើយ៉ាងណាទើបការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធក្នុងករណីខេត្តព្រៃវែង មានលក្ខណៈពេញលេញ នឹងទទួលបានជោគជ័យ។

ម្យ៉ាងវិញទៀតកិច្ចសារណាដែលលោក សាស្ត្រាចារ្យនិងមិត្តៗ និស្សិតកំពុងកាន់នៅនឹងដៃនេះប្រាកដ ជាមានចំណុចខ្វះខាតដែលកើតមានឡើងដោយឥតព្រៀងទុកជាមិនខាន ហេតុនេះហើយនាងខ្ញុំសូមការអភ័យទោសពីសំណាក់ អ្នកទាំងអស់គ្នាដោយក្តីអនុគ្រោះផង តទៅមុខទៀតនាងខ្ញុំសង្ឃឹមយ៉ាងប្រត្យក្សថានឹង ទទួលបាននូវយោបល់កែលំអរពីអ្នកទាំងអស់គ្នាដើម្បីធ្វើការកែប្រែអោយប្រសើរនូវស្នាដៃមួយនេះ រួមនិងស្នាដៃផ្សេងទៀតដែលនិងកើតឡើងជាបន្តបន្ទាប់។

# មាតិកា

**សេចក្តីផ្តើម ........................................................................................................................១**

## ជំពូកទី១

## ស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន និង ស្ថានភាពទូទៅនៃតំបន់ពិភាក្សាខេត្តព្រៃវែង

**១.១. ស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន ..........................................៤**

**១.១.១. ស្ថានភាពដីធ្លីនាពេលបច្ចុប្បន្ន.. ...........................................................................................៤**

១.១.២. ប្រវត្តិសង្ខេបនៃការកាន់កាប់ដីធ្លីនៅកម្ពុជា ...............................................................................៦

១.១.៣. ការរៀបចំផែនការការងារនៅក្នុងតំបន់វិនិច្ឆ័យ .......................................................................... ៨

១.១.៤. បទដ្ឋានគតិយុត្តដែលគាំទ្រដល់ដំណើរការវិនិច្ឆ័យ ...................................................................... ៨

១.១.៥. សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី.......................................................... ៩

១.១.៦. តម្លៃសេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ .......................................................................១០

**១.២. ស្ថានភាពទូទៅនៃតំបន់ពិភាក្សាខេត្តព្រៃវែង.....................................................................១១**

១.២.១. អំពីភូមិសាស្ត្ររបស់ខេត្តព្រៃវែង.. ...........................................................................................១១

១.២.២. ស្ថានភាពទូទៅនៃស្រុកកំចាយមារ. ..........................................................................................១២

១.២.៣. ប្រជាជន និង មុខរបរ.. .........................................................................................................១៣

## ជំពូកទី២

## ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅខេត្តព្រៃវែង

**២.១. ដំណាក់កាលត្រៀមរៀបចំ.. ................................................................................................១៤**

២.១.១. អភិបាលខេត្តស្នើសុំក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់.............................................១៤

២.១.២. អភិបាលខេត្តចេញសេចក្តីសម្រេចកំណត់តំបន់វិនិច្ឆ័យ..................................................................១៥

២.១.៣. អភិបាលខេត្តចេញសេចក្តីសម្រេចបង្កើតគណៈកម្មការ ...................................................................១៥

២.១.៤. កិច្ចប្រជុំពិភាក្សាកំណត់ព្រំប្រទល់ ...........................................................................................១៧

២.១.៥. កិច្ចប្រជុំបើកវគ្គបណ្តុះបណ្តាល . ..............................................................................................១៨

**២.២. ដំណាក់កាលប្រតិបត្តិការបច្ចេកទេស ........................................ ១៨**
**២.២.១. ការងារវាល ........................................ ១៩**
២.២.១.១. ការកំណត់ព្រំដី ........................................ ១៩
២.២.១.២. ការវាស់វែង ........................................ ២០
២.២.១.៣. ការវិនិច្ឆ័យ ........................................ ២០
**២.២.២. ការងារការិយាល័យ ........................................ ២៣**
**២.៣. ដំណាក់កាលការបិទផ្សាយជាសាធារណៈ ........................................ ២៥**
២.៣.១. យុទ្ធនាការផ្សព្វផ្សាយ ........................................ ២៦
២.៣.២. រយៈពេលនៃការផ្សព្វផ្សាយ ........................................ ២៦
២.៣.៣. ឯកសារតម្រូវ ........................................ ២៧
២.៣.៤. ភារកិច្ច និង ទំនួលខុសត្រូវរបស់មន្ត្រីវិនិច្ឆ័យ ........................................ ២៧
២.៣.៥. បណ្ដឹងជំទាស់ និង ការសម្រុះសម្រួល ........................................ ២៧
**២.៤. ការសម្រេចលើឯកសារ ........................................ ២៩**
**២.៥. ការចេញប័ណ្ណ ........................................ ៣១**
២.៥.១. គោលការណ៍នៃការចេញប័ណ្ណ ........................................ ៣១
២.៥.២. នីតិវិធីក្នុងការចែកប័ណ្ណ ........................................ ៣៣

## ជំពូកទី៣

## បញ្ហាប្រឈម ដំណោះស្រាយ និង ផលប្រយោជន៍នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងខេត្តព្រៃវែង

**៣.១. បញ្ហាប្រឈម ........................................ ៣៥**
៣.១.១. ដីទំនាស់ ........................................ ៣៥
៣.១.២. ស្ថានភាពភូមិសាស្ត្រ ........................................ ៣៦
៣.១.៣. សំភារៈ ........................................ ៣៦
៣.១.៤. ពេលវេលា ........................................ ៣៦
៣.១.៥. សង្គ្រាម ........................................ ៣៧
៣.១.៦. ចំណេះដឹង ផ្នែកច្បាប់ និង ច្បាប់ ........................................ ៣៧
៣.១.៧. ការអនុវត្តមិនត្រឹមត្រូវរបស់មន្ត្រីអនុវត្ត ........................................ ៣៨

៣.១.៨. ឯកសារ ............................................................................................................ ៣៨
៣.១.៩. ថវិកា....................................................................................................................... ៣៩
**៣.២. ដំណោះស្រាយ.. ........................................................................................................... ៣៩**
**៣.៣. ផលប្រយោជន៍...........................................................................................................៤០**
**សេចក្តីសន្និដ្ឋាន .......................................................................................................................៤១**
**អនុសាសន៍..............................................................................................................................៤២**
**គន្ថនិទ្ទេស**

# អក្សរកាត់

ADB: Asian Development Bank

LMAP: Land Management and Administration Project

WTO: World Trade Orgeanization

PPMO: Provincial Project Management Offices

LASSP: Land Administration Sub Sector Program

CPMO: Central Planning Management Office

PACP: Public Awareness And Community

PACM: Pan-Africanist Community Movement

# បញ្ជីតារាង

តារាង១៖ គោលបំណងរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការដីធ្លី, ៩

តារាង២៖ តម្លៃសេវានៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធ, ១១

តារាង៣៖ សមាសភាព មុខងារ សិទ្ធិនិងភារកិច្ចរបស់គណៈកម្មការរដ្ឋបាល, ១៦

តារាង៤៖ សិទ្ធិ និងភារកិច្ចមន្ត្រីកំណត់ព្រំដី និង មន្ត្រីវិនិច្ឆ័យ, ២១

តារាង៥៖ សិទ្ធិ និងភារកិច្ចអ្នកកាន់កាប់ដី និង អាជ្ញាធរដែនដី, ២២

តារាង៦៖ ទិន្នន័យត្រួតពិនិត្យគុណភាពក្បាលដី, ២៣

តារាង៧៖ បញ្ហាលើការងារនៅវាល និងនៅការិយាល័យ, ២៤

តារាង៨៖ លទ្ធផលបូកសរុបក្បាលដីមុនពេលបិទផ្សាយ, ២៥

តារាង៩៖ បណ្តឹងជំទាស់ និងការសម្រុះសម្រួល, ២៨

តារាង១០៖ លទ្ធផលសម្រេចលើឯកសារក្រោយពេលបិទផ្សាយ, ២៩

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានក្រលាផ្ទៃ ១៨១.០៣៥ គីឡូម៉ែត្រការេ ស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍នៃអាស៊ីមូសុង គឺក្នុងភូមិភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិនដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ឡាវ ថៃ និងមានប្រជាជនរស់នៅប្រមាណជាង ១៣ លាននាក់ព្រមទាំងមានការគ្រប់គ្រងដីធ្លី ទៅតាមការវិវត្តនៃដំណាក់កាលនីមួយៗ ជាក់ស្តែងកាលពីសម័យមុន "ការគ្រប់គ្រងទៅលើប្រព័ន្ធនៃការកាន់កាប់ដី និងការប្រើប្រាស់ដី គឺព្រះមហាក្សត្រជាម្ចាស់គ្រប់គ្រងទាំងស្រុង"[1] ជាហេតុធ្វើឲ្យមានផលវិបាកដល់ប្រជាជនក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លី ដែលមិនមែនជារបស់ខ្លួន។

ការវិវត្តពីសម័យកាលមួយ ទៅសម័យកាលមួយនៃប្រទេសកម្ពុជាចេះតែវិលទៅមុខឥតឈប់ឈរ រហូតមកដល់ការបញ្ចប់សង្គ្រាមនៅឆ្នាំ ១៩៧៩ និងក្រោយឆ្នាំ១៩៨៩ធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជារិតតែអាចកត់សម្គាល់ ឃើញថាមានបញ្ហាជាច្រើន ដែលធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ បញ្ហាចម្បងនោះគឺការកាន់កាប់ដីធ្លី តម្រូវឲ្យរាជរដ្ឋាភិបាលដោះស្រាយជាបន្ទាន់ដូចជាជម្លោះ ក្នុងការដណ្តើមសិទ្ធិកាន់កាប់ ជម្លោះព្រំដី ការរឹបអូសយកដីរបស់ប្រជាពលរដ្ឋពីសំណាក់អ្នកមានអំណាច និងទន្ទ្រានកាន់កាប់ដោយខុសច្បាប់យកដីព្រៃជាដើម។ បញ្ហាទាំងអស់នេះមកពី កង្វះខាតផ្នែកច្បាប់ ជាពិសេសភាពមិនច្បាស់លាស់ខាងផ្នែកច្បាប់លើសិទ្ធិដីធ្លី។ ដោយឃើញនូវបញ្ហានិងផលវិបាកជាច្រើនរបស់ប្រជាជនក្នុងការកាន់កាប់ និង គ្រប់គ្រងដីធ្លីរបស់ខ្លួនបែបនេះហើយ ទើបនៅឆ្នាំ១៩៧៩ និងក្រោយឆ្នាំ១៩៨៩ "រដ្ឋាភិបាលកម្ពុជាក៏បានរៀបចំចងក្រងនូវបទដ្ឋានគតិយុត្តជាច្រើនដើម្បីអាចទ្រទ្រង់ការងារដីធ្លីដូចជា ច្បាប់ភូមិបាលឆ្នាំ១៩៩២ច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ និងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ក្រៅពីនោះរដ្ឋាភិបាលកម្ពុជាកំពុងតែខិតខំជំរុញឲ្យសម្រេចបាននូវ គោលដៅជាតិនៃការអភិវឌ្ឍសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និង អភិបាល

[1] Matthew Rendall, Josee Tremblay និង Patricia, *ច្បាប់ភូមិបាលកម្ពុជា និងសៀវភៅស្រាវជ្រាវ* (ភ្នំពេញ៖ East-West management institute, 2005), ២២ (ពីពេលនេះតទៅហៅថាច្បាប់ភូមិបាលកម្ពុជា និងសៀវភៅស្រាវជ្រាវ ២០០៥)។

កិច្ចល្អ"[2]។ ជាមួយគ្នានេះដែរ "ដើម្បីសម្រេចគោលដៅនេះរាជរដ្ឋាភិបាល បានខិតខំធ្វើឲ្យបានសម្រេចកិច្ចការសំខាន់ៗរួមមាន ផ្នែករដ្ឋបាលដីធ្លី ផ្នែករៀបចំដែនដី និងផ្នែកបែងចែកដីធ្លី"[3]។

លើសពីនេះទៅទៀត លើផ្នែករដ្ឋបាលដីធ្លីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បានបង្កើតគម្រោងរៀបចំដែនដី និង រដ្ឋបាលដីធ្លីដោយផ្អែកលើមូលដ្ឋានបទពិសោធន៍ ពីគម្រោងសាកល្បងចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដើម្បីចេញវិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុឲ្យបានមួយលានក្បាលដីក្នុងដំណាក់កាលទីមួយចាប់ពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៧។ ក្រោមគម្រោងសាកល្បងចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះដែរ បានទទួលការ "គាំទ្រដោយដៃគូអភិវឌ្ឍប្រទេសហ្វាំងឡង់ និងអាល្លឺម៉ង់ បានក្លាយទៅជាកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីក្នុងទិសដៅពន្លឿនដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដើម្បីធានាឲ្យបាននូវសុវត្ថិភាពនៃការកាន់កាប់ដី និងកាត់បន្ថយជម្លោះដីធ្លី"[4]។

អាស្រ័យតាមការបង្ហាញពីបញ្ហានានាខាងលើនេះ ក៏ដូចជាដើម្បីឲ្យការកំណត់ទិសដៅរបស់រាជរដ្ឋាភិបាលឲ្យមានស្ថិរភាពក្នុងសង្គម និង លើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយភាពក្រីក្រថែមទៀតនោះ ហេតុដូចនេះទើបលើកយកប្រធានបទមួយមកធ្វើការពិភាក្សាគឺៈ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (ករណីខេត្តព្រៃវែង) មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណង ស្វែងយល់ពីខ្លឹមសារនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ស្វែងយល់ពីដំណាក់កាលនីមួយៗនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធឲ្យបានច្បាស់លាស់ និងជាពិសេសគឺស្វែងរកផលវិបាកនានាក្នុងព្រឹត្តិការណ៍ជាក់ស្តែង គួបផ្សំទៅនិងដំណោះស្រាយ ទៅលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (ករណីខេត្តព្រៃវែង)ផងដែរ។

ការស្រាវជ្រាវនេះផ្តោតទៅលើទិដ្ឋភាពជាក់ស្តែង នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធទៅលើតំបន់មួយស្ថិតនៅភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែងនាពេលបច្ចុប្បន្ន។

---

[2]បទសម្ភាសជាមួយនឹងអនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដីខេត្តព្រៃវែង (ទទួលបន្ទុកការងារសុរិយោដី និងភូមិសាស្ត្រខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន (២០ ឧសភា ២០១៨)។

[3] ឯកសារស្រាវជ្រាវស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី, ៦ ខែកញ្ញា ២០០២, ៥ ដល់ ៧។

[4] អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ,*ឯកសារបណ្តុះបណ្តាលការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ* (ហ្វាំងឡង់ និងកាណាដា ៖ មីនា ឆ្នាំ២០០៨)។

សារណានេះបែងចែកជាបីជំពូក។ ជំពូកទី១ បង្ហាញអំពីស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន និង ស្ថានភាពទូទៅនៃតំបន់ពិភាក្សាខេត្តព្រៃវែង។ ចំណែកជំពូកទី២ ពិភាក្សាអំពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅខេត្តព្រៃវែង រីឯជំពូកទី៣វិញ ពិភាក្សាអំពីបញ្ហាប្រឈម ដំណោះស្រាយ និងផលប្រយោជន៍នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងខេត្តព្រៃវែង។

# ជំពូកទី១
# ស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន និង ស្ថានភាពទូទៅនៃតំបន់ពិភាក្សាខេត្តព្រៃវែង

## ១.១. ស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន

### ១.១.១. ស្ថានភាពដីធ្លីនាពេលបច្ចុប្បន្ន

ប្រទេសកម្ពុជា មានទីតាំងស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍នៃឧបទ្វីបឥណ្ឌូចិន ហើយមានបណ្តោយពីលិចទៅកើតប្រវែង៥៦០គ.ម ពីជើងទៅត្បូង ៤៤០គ.ម។ ប្រទេសកម្ពុជាមានផ្ទៃដីសរុប ១៨១.០៣៥គ.ម²។ ជាការប៉ាន់ស្មានក្នុងឆ្នាំ២០០៣ ដីប្រមាណ១៨លានហិចតា ក្នុងនោះ៨លានហិចតាជាដីសម្បទាន ៣.៣លានហិចតាជាដីព្រៃបម្រុងទុក ២.៧ហិចតាជាដីដាំដុះ ចំណែកដីនៅសល់គឺមាន ដីព្រៃរបោះ ផ្លូវទឹក ដីសម្រាប់សាងសង់គ្រប់ប្រភេទ និង ដីទុកចោលដោយសារគ្រាប់មីន។ ស្ថានភាពនៃការកាន់កាប់ និង ប្រើប្រាស់ដីធ្លីនៅប្រទេសកម្ពុជា មានការវិវត្តពីសម័យកាលមួយទៅសម័យកាលមួយ តាមការអនុវត្តនៃស្ថានភាពនយោបាយ និង សេដ្ឋកិច្ចសង្គមរបស់ប្រជាជន។ តាមការប៉ាន់ស្មានក្នុងការអង្កេតទៅលើសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ១៩៩៩ បង្ហាញថា "ប្រជាពលរដ្ឋកម្ពុជាមាន ២.០៩៣.១៥២គ្រួសារ នៅក្នុងនោះ ១.៧៨២.៣៥០ គ្រួសាររស់នៅតាមជនបទ ហើយអ្នកនៅសល់នៅតាម ទីប្រជុំជននានា ចំពោះដីកសិកម្មនៅឆ្នាំ១៩៩៩ មានទំហំ ២.៨៨ លានហិចតា តាមរយៈតួលេខនេះមានន័យថាគ្រួសារនីមួយៗអាចមានដីកសិកម្ម ១.៣៧ ហិចតា ដីលំនៅឋានសរុប ២.០២៩.៦០ក្បាលដី ដែលក្បាលដីនីមួយៗមានទំហំជាមធ្យម៨៨៨ ម៉ែត្រក្រឡា"[5]។

រហូតមកដល់សហាសវត្សរ៍ឆ្នាំ២០០០ ប្រទេសកម្ពុជាជាប្រទេសមួយដែលនៅតែពឹងផ្អែកលើវិស័យកសិកម្មជាចម្បង សម្រាប់ជាមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច ទោះបីមានការរីកដុះដាលនៃឧស្សាហកម្មវាយនភ័ណ្ឌនារយៈពេលចុងក្រោយនេះក៏ដោយ ក៏មិនអាចកាត់ផ្តាច់ចេញពីវិស័យកសិកម្មបានដែរ។ កសិករប្រមាណ៧៥% រស់នៅតាមជនបទបានពឹងផ្អែកទៅលើដីរបស់ខ្លួនដើម្បីបង្កបង្កើនផល ក្នុងពេលដែលកសិកម្មបែបប្រពលវប្បកម្ម និង ពហុវប្បកម្មមិនទាន់បាន

[5] ដូច២។

អភិវឌ្ឍឲ្យបានទូលំទូលាយ រួមផ្សំនិងការកសាងប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត កសិករភាគច្រើននៅតែធ្វើស្រែដោយប្រវាសនឹងមេឃនៅឡើយ។ ដូច្នេះវាពិតជាទាមទារតម្រូវការដី ឲ្យបានធំទូលំទូលាយដើម្បីធ្វើអាជីវកម្មសម្រាប់យកផលចិញ្ចឹមជីវិតឲ្យបានពេញមួយឆ្នាំ ពីព្រោះគេមិនបានប្រើប្រាស់ដីនោះសម្រាប់ដំនាំអ្វីផ្សេងទៀតបានឡើយ ដោយសារគ្មានទឹក ពោលគឺប្រជាកសិករអាចធ្វើបានតែនៅ រដូវវស្សាដែលមានទឹកតែប៉ុណ្ណោះ និង ទុកដីនោះឲ្យទំនេរនៅរដូវប្រាំង។ ក្រៅពីធ្វើការស្រែចំការ ប្រជាពលរដ្ឋខ្មែរបានផ្សាភ្ជាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន ទៅនឹងធនធានធម្មជាតិដែលនៅជុំវិញខ្លួនពួកគេ និង នៅជិតកន្លែងដែលពួកគេរស់នៅ ជាតម្រូវការចាំបាច់មិនអាចខ្វះបាន ដើម្បីបង្គ្រប់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាតម្រូវការដើបម្រុងទុក កំណើននៃគ្រួសារនាពេលអនាគត។ ស្ថានភាពនៃការគ្រប់គ្រងដីធ្លីបច្ចុប្បន្នបាននឹង កំពុងគំរាមកំហែងយ៉ាងខ្លាំងទៅដល់កសិករក្រីក្រនៅតាមជនបទដោយពួកគេកាន់តែប្រឈមថែមទៀតទៅនឹង ភាពគ្មានដីដោយសារកត្តាជាច្រើនដូចជា ការប្រកួតប្រជែងទីផ្សារដី ភាពក្រីក្រ គ្រោះថ្នាក់ធម្មជាតិ និង ការរំលោភយកដីជាដើម "ប្រជាពលរដ្ឋកម្ពុជាប្រមាណ១៥% បានក្លាយជាអ្នកគ្មានដី។ បច្ចុប្បន្នគេសង្កេតឃើញមានចរន្តបីបានកើតឡើងរួមគ្នា ចរន្តទី១ គឺអ្នកគ្មានដី និងអ្នកបាត់បង់ដី ចរន្តទី២ អ្នកមានដីមធ្យមអាចបង្កបង្កើនផលបាន និង ចរន្តទី៣ គឺអ្នកមានដីធំដោយប្រមូលយកដីទុកឲ្យនៅទំនេរដើម្បីលក់យកចំណេញពេលក្រោយ"[6]។ ចេញពីចរន្តទាំងបីនេះហើយ ទើបអាចធ្វើឲ្យសង្គមកម្ពុជាបច្ចុប្បន្នបានលេចឡើង នូវវិវាទដីធ្លីគួរឲ្យព្រួយបារម្ភ រហូតដល់ប្រមុខរាជរដ្ឋាភិបាលប្រមាណថា ប្រសិនបើគ្មានការយកចិត្តទុកដាក់ទេនោះ បដិវត្តកសិករអាចនឹងផ្ទុះឡើងដោយមិនអាចគេចវេះបានឡើយ។

ដោយសារដីធ្លីជាធនធានកម្រ មានន័យថាដីធ្លីមិនអាចកើតឡើងទេ ដូច្នេះយុទ្ធសាស្ត្រនៃការអភិវឌ្ឍសេដ្ឋកិច្ច កម្ពុជាពឹងផ្អែកលើធនធានដីចាំបាច់ ត្រូវធ្វើទំនើបភាវូបនីយកម្មព្រមទាំងវិស័យកសិកម្មតាមរយៈការធ្វើប្រពលវប្បកម្ម កសិឧស្សាហកម្ម ពាណិជ្ជកម្ម ដោយការផ្សាភ្ជាប់រវាងកសិដ្ឋានខ្នាតធំ និង ខ្នាតតូច ដើម្បីធានាឲ្យមានការងារធ្វើនៅជនបទ ការកែច្នៃផលិតផលមុននាំចេញដើម្បីបង្កើនតម្លៃ នឹងការប្រកួតប្រជែងជាមួយទីផ្សារក្នុងតំបន់ និង នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកWTO ដូច្នេះរដ្ឋត្រូវគ្រប់គ្រងដីធ្លីរបស់រដ្ឋ ឲ្យបានល្អដើម្បីបម្រើដល់ការវិនិយោគលើវិស័យនេះ។ ការកំណត់សិទ្ធិដើម្បីឈានដល់ការប្រគល់សិទ្ធិជាកម្មសិទ្ធិគឺ ជាកិច្ចចម្បងក្រោម

[6] ដូច២។

ការអនុវត្តក្របខ័ណ្ឌគតិយុត្តដែលអាចធ្លោះទៅធានាបាន នូវសុវត្ថិភាពលើការកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ។

### ១.១.២. ប្រវត្តិសង្ខេបនៃការកាន់កាប់ដីធ្លីនៅកម្ពុជា

ការកាន់កាប់ដីធ្លីនៅកម្ពុជា "នៅក្នុងសម័យមុនអាណានិគម ដីគឺជាសម្បត្តិរបស់ព្រះមហាក្សត្រ ប៉ុន្តែប្រជាជនអាចធ្វើការដាំដុះដោយសេរីលើដីធ្លីតាមទំហំដែលខ្លួនត្រូវការ។ ប៉ុន្តែដោយសាខ្វះលទ្ធភាពខាងមធ្យោបាយផលិតកម្ម ការកាន់កាប់ដីធ្លីជាលក្ខណៈឯកជន គឺមិនលើសពី ១ទៅ៣ ហិចតាឡើយ"[7]។ ម្យ៉ាងវិញទៀតនៅពេលនោះប្រជាជនមានចំនួនតិច ហើយគ្មានទីផ្សារដីធ្លីដូចសព្វថ្ងៃទេ ជាហេតុធ្វើឲ្យប្រជាកសិករអាចចល័តពីកន្លែងមួយទៅកន្លែងមួយ និងអាចកាន់កាប់ដីធ្លីបានដោយសេរី។ ម្ចាស់ដីមានសិទ្ធិផ្តាច់មុខក្នុងការកាន់កាប់ប្រើប្រាស់ ឬ បន្តមរតកដីកសិកម្មដោយមិនចាំបាច់ត្រូវបំពេញសំណុំបែបបទអ្វី ក្រៅអំពីការបង់ពន្ធជាស្វយសារអាករតូចមួយទៅឲ្យសក្តិភូមិនោះទេ។ ចាប់ពីក្នុងរង្វង់ឆ្នាំ១៨០០ ដល់ឆ្នាំ១៩៣០ អាណានិគមបារាំងព្យាយាមដាក់បញ្ចូលនូវប្រព័ន្ធទ្រព្យសម្បត្តិឯកជន និងកម្មសិទ្ធិជាផ្លូវការ ប៉ុន្តែការងារនេះមិនបានជោគជ័យទាំងស្រុងទេ។ បារាំងធ្វើបានសម្រេចខ្លះៗ នៅក្នុងតំបន់វាលទំនាប ធ្វើស្រែ ប៉ុន្តែផ្ទៃដីធំល្វឹងល្វើយក្រៅពីវាលទំនាប(ដូចជាដីព្រៃ និង ដីចំការតំបន់ខ្ពង់រាប) ត្រូវបានរំលងចោល។ នៅក្រោយសម័យអាណានិគម(ឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧៥) ប្រទេសកម្ពុជាបានបន្តប្រើប្រាស់ប្រព័ន្ធដីធ្លី ដែលបារាំងដាក់ឲ្យប្រើ ហើយដូចមុនដែរការចងក្រងច្បាប់ការងារធ្វើឯកជនភាវូបនីយកម្ម និង ការធ្វើពាណិជ្ជកម្មដីធ្លីបានជោគជ័យតែមួយកម្រិតតែប៉ុណ្ណោះ។ របបខ្មែរក្រហម (១៩៧៥ដល់ឆ្នាំ១៩៧៩) បានដកហូតយកដីទាំងអស់ដាក់ជាដីសមូហភាព។ ដីឯកជនភាវូបនីយកម្មបានចាប់ផ្តើមជាថ្មី នៅពាក់កណ្តាលទស្សវត្សរ៍ឆ្នាំ១៩៨០ និងបានចូលជាផ្លូវការនៅឆ្នាំ១៩៨៩។ ចាប់ពីពេលនោះមក គឺប្រជាជនទាំងកសិករ និង មិនមែនជាកសិករអាចចូលកាន់កាប់ដីឯកជនបើពួកគេប្រើប្រាស់ដីទាំងនេះ។[8]

សម្រាប់ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលរងនូវការខ្ទេចខ្ទាំដោយសារសង្គ្រាម អ្វីៗទាំងអស់ត្រូវចាប់ផ្តើមឡើងវិញសារជាថ្មីទាំងធនធានមនុស្ស និង សំភារៈបច្ចេកទេសត្រូវធ្វើការបណ្តុះបណ្តាល និង រៀបចំឡើងវិញទាំងអស់។ នៅក្នុងឆ្នាំ១៩៩២ រដ្ឋាភិបាលកម្ពុជាបានតាក់តែងច្បាប់

[7] ច្បាប់ភូមិបាលកម្ពុជា និងសៀវភៅស្រាវជ្រាវ ២០០៥។
[8] ដូច២។

ភូមិបាលមួយឡើង សម្រាប់គ្រប់គ្រងសិទ្ធិកាន់កាប់ដី ដោយបានធ្វើការបែងចែកដីមួយផ្នែកឲ្យក្លាយទៅជាសម្បត្តិឯកជន និងមួយផ្នែកទៀត ជាសម្បត្តិរបស់រដ្ឋ។ ពិតមែនតែរដ្ឋបានប្រគល់ដីមួយផ្នែកទៅឲ្យប្រជាពលរដ្ឋជាអ្នកកាន់កាប់ក៏ពិតមែននៅពេលនោះ ប៉ុន្តែរដ្ឋបានកំណត់ទំហំដីសម្រាប់ការកាន់កាប់ ដោយកំណត់ដីលំនៅឋានមានទំហំត្រឹមតែ ២.០០០ ម៉ែតក្រលា និងដីផលិតកម្មកសិកម្ម មិនឲ្យលើសពី៥ហិចតាទេ សម្រាប់កាន់កាប់និងប្រើប្រាស់។ លុះមកដល់ឆ្នាំ ២០០១ ដោយមានការកែប្រែរបបនយោបាយ រដ្ឋាភិបាលបានចេញច្បាប់ភូមិបាលថ្មីមួយទៀត ដើម្បីធ្វើការកំណត់ដីធ្លី ដែលបានប្រែក្លាយសិទ្ធិពីភោគៈ ឲ្យទៅជាកម្មសិទ្ធិចំពោះការកាន់កាប់ណាដែលគោរពបានតាមមាត្រា ៣៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

លើសពីនេះទៅទៀត ដោយពិនិត្យឃើញថា បញ្ហាដីធ្លីជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ និងទប់ស្កាត់នៅរាល់ការចូលទន្ទ្រានកាន់កាប់ដោយខុសច្បាប់លើដីរដ្ឋ ដីឯកជនផ្សេងទៀត ហើយកាត់បន្ថយនូវរាល់ជម្លោះដីធ្លី ដែលកើតមានឡើងជាញឹកញាប់ផងនោះរាជរដ្ឋាភិបាលបានបង្កើតក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ដែលជាស្ថាប័នរដ្ឋគ្រប់គ្រង និងដោះស្រាយរាល់បញ្ហាទាក់ទងដីធ្លី។ ក្នុងការជំរុញដោះស្រាយបញ្ហាដីធ្លី ការផ្តល់សុវត្ថិភាពលើការកាន់កាប់និងប្រើប្រាស់ គឺជាផ្នែកមួយដ៏ចម្បងរបស់ក្រសួង ហើយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្រ្តបានខិតខំបំពេញភារកិច្ច និងកិច្ចចម្បងៗរួមមាន ផ្នែករដ្ឋបាលដីធ្លី ផ្នែករៀបចំដែនដី និងបែងចែកដីធ្លី ត្រូវអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយធ្វើការសម្រេចចេញនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនទៅប្រជាពលរដ្ឋ។

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគឺពឹងផ្អែកលើអនុក្រឹត្យលេខ ៤៦អនបក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីនិងសារាចរណែនាំអនុវត្តលេខ ០០១ ដនសសដ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២ កំណត់លម្អិតពីដំណាក់កាលនីមួយៗនៃការចុះបញ្ជីដីធ្លី។ ដំណើរការនៃការចុះបញ្ជីដីធ្លីនេះ ត្រូវបានអភិវឌ្ឍឡើងដើម្បីធានានូវតម្លាភាពខ្ពស់បំផុត នៃការផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយ ធ្វើយ៉ាងណាដើម្បីធានាសុវត្ថិភាពទៅលើការកាន់កាប់ដីធ្លីដល់ប្រជាពលរដ្ឋ។ អចលនវត្ថុទាំងអស់របស់ឯកជននិងត្រូវបានចុះបញ្ជី ហើយរាល់ក្បាលដីនីមួយៗនឹងត្រូវបានចុះទៅអង្កេតមើលម្តងមួយៗ និងមានការកត់ត្រាតាមការផ្តល់ចម្លើយផ្ទាល់មាត់ ឯកសារណេប និងលិខិតពាក់ព័ន្ធផ្សេងៗជាភស្តុតាង។ លើសពីនេះនីតិវិធីនេះ មានផែនការធ្វើឲ្យមានការចំណាយប្រាក់ទាបមានប្រសិទ្ធភាពខ្ពស់។

### ១.១.៣. ការរៀបចំផែនការការងារនៅក្នុងតំបន់វិនិច្ឆ័យ

ដើម្បីឲ្យការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ អាចមានដំណើររការទៅបានល្អប្រសើរនិងមានការចូលរួមយ៉ាងពេញទំហឹងនិងកក់ក្ដៅពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក៏ដូចជាអាជ្ញាធរមូលដ្ឋានផ្ទាល់ផងនោះ មន្រ្តីផ្សព្វផ្សាយ និង រៀបចំដែនដីសហាការយ៉ាងជិតស្និតជាមួយអាជ្ញាធរទាំងនោះ រួមទាំងប្រជាពលរដ្ឋម្ចាស់ដី ឬអ្នកកាន់កាប់ទាំងអស់ទាំងអ្នកដែលមានដី អ្នកដែលអត់ដី និងអ្នកដែលបោះទីតាំងលើដីចំណីសាធារណៈផងដែរ។

ម្យ៉ាងវិញទៀត "ដើម្បីឲ្យការអនុវត្តការងារនៅក្នុងតំបន់វិនិច្ឆ័យទទួលបានជោគជ័យ មន្ត្រីផ្សព្វផ្សាយនៃសមាសភាពរងទី១ ត្រូវផ្តោតជាសំខាន់ទៅលើការប្រមូលទិន្នន័យលើប្រវត្តិដីភូមិការផ្សព្វផ្សាយពិតមានអំពីច្បាប់ភូមិបាល នីតិវិធីនៃការចុះបញ្ជីដីធ្លីទៅសាធារណៈជន សម្រាប់ម្ចាស់ដី ឬអ្នកកាន់កាប់ដី និងមន្ត្រីនៅថ្នាក់ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ រាជធានី ខេត្ត ក្រុង និងថ្នាក់ជាតិ គឺធ្វើយ៉ាងណាឲ្យការផ្សព្វផ្សាយនេះ បានទូលំទូលាយទៅដល់ប្រជាពលរដ្ឋ និងធ្វើឲ្យពួកគាត់បានយល់ដឹងហើយនាំការយល់ដឹងរបស់ពួកគាត់ មកធ្វើការចុះបញ្ជីដោយស្ម័គ្រចិត្ត ជាឯកសារស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធវគ្គទី២ ឆ្នាំ២០០៥"[៩] ។

### ១.១.៤. បទដ្ឋានគតិយុត្តដែលគាំទ្រដល់ដំណើរការវិនិច្ឆ័យ

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺជាការចុះបញ្ជីនូវរាល់ក្បាលដីទាំងអស់ដែលមាននៅក្នុងតំបន់មួយ ដែលបានកំណត់ថាជាតំបន់ធ្វើការវិនិច្ឆ័យ។ លទ្ធផលនៃការចុះបញ្ជីដីធ្លីនេះ និងទទួលបាននូវពិតមានត្រឹមត្រូវស្របច្បាប់ ដែលឈានទៅដល់ការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ប័ណ្ណកម្មសិទ្ធិ ទៅឲ្យម្ចាស់ដី អ្នកកាន់កាប់ដី (សារាចរណែនាំលេខ ០០១ ដនស សជ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី)។

[៩] ដូច២។

## ១.១.៥. សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី

រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំជំរុញការអនុម័ត និងអនុវត្តកម្រងច្បាប់ កម្មវិធីការងារ និងការសម្របសម្រួលស្ថានភាពដែលពាក់ព័ន្ធទៅ នឹង ការងារដីធ្លីសំដៅជំរុញឲ្យសម្រេចបាននូវគោលដៅជាតិនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច យុទ្ធសាស្ត្របណ្តោះអាសន្ន សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អដូចមានចែងក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច យុទ្ធសាស្ត្របណ្តោះអាសន្ន សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងផែនការសកម្មភាពអភិបាលកិច្ចល្អ។

គោលបំណងនៃសេចក្តីប្រកាសនេះគឺ ពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងទីផ្សារដីធ្លី និងទប់ស្កាត់ ឬដោះស្រាយទំនាស់ដីធ្លីទាំងឡាយ រៀបចំដែនដី និងគ្រប់គ្រងធនធានធម្មជាតិដោយសមធម៌ ចីរភាព និងមានប្រសិទ្ធភាព ព្រមទាំងជំរុញការបែងចែកដីធ្លីប្រកបទៅដោយសមធម៌។[10]

ដើម្បីសម្រេចគោលបំណងក្នុងការជំរុញធ្វើយ៉ាងណា ឲ្យមានលក្ខណៈល្អប្រសើរលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ រាជរដ្ឋាភិបាលបានខិតខំធ្វើឲ្យសម្រេចកិច្ចការមួយចំនួនដូចជាកិច្ចការងារលើផ្នែករដ្ឋបាលដីធ្លី ផ្នែករៀបចំដែនដី និងផ្នែកបែងចែកដីធ្លី។ តារាងខាងក្រោមនេះនឹងបញ្ជាក់ពីសេចក្តីលម្អិតទៅលើកិច្ចការងារលើផ្នែករដ្ឋបាលដីធ្លី ផ្នែករៀបចំដែនដី និងផ្នែកបែងចែកដីធ្លី៖

តារាង១៖ គោលបំណងរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការដីធ្លី[11]

| ផ្នែករដ្ឋបាលដីធ្លី | ផ្នែករៀបចំដែនដី | ផ្នែកបែងចែកដីធ្លី |
|---|---|---|
| អនុម័ត និង អនុវត្តច្បាប់ភូមិបាល អាចជាច្បាប់បំពេញបន្ថែមលិខិតបទដ្ឋាន និង ច្បាប់ពាក់ព័ន្ធដទៃទៀត។<br>ប្រតិបត្តិការ លើការងាររបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីជំរុញ និង ត្រួតពិនិត្យទៅលើការអនុវត្ត នយោបាយដីធ្លី ឲ្យបានត្រឹមត្រូវតាមទិសដៅ របស់ឧត្តមក្រុមប្រឹក្សា | អភិវឌ្ឍន៍លើផែនការប្រើប្រាស់សម្រាប់ តំបន់អាទិភាពនានា រួមមានតំបន់ទេសចរណ៍ តំបន់វិនិយោគ តំបន់ទីប្រជុំជន និងតំបន់តាមដងផ្លូវសំខាន់ៗ។<br>សម្របសម្រួល ផែនការប្រើប្រាស់ដីធ្លីជាមួយនឹងការគ្រប់គ្រងធនធានធម្មជាតិ ដូចជាព្រៃឈើ | អនុវត្តដំណើរការពិគ្រោះយោបល់ ទូលំទូលាយ និងគម្រោងសាកល្បងនានាដើម្បីជួយដល់ការបង្កើតយុទ្ធសាស្ត្របែងចែកដីធ្លីដល់ប្រជាពលរដ្ឋដែលត្រូវការ។ |

[10] ដូច៣, ទំព័រ៦។

[11] ដូច៣, ទំព័រ៦ ដល់៧។

| | | |
|---|---|---|
| កំណែទម្រង់រដ្ឋ។ បង្កើតបញ្ជីសារពើភ័ណ្ឌនិង រៀបចំប្រព័ន្ធ ចំណាត់ថ្នាក់ដីរដ្ឋ។ អនុវត្តលើការចុះបញ្ជីដីធ្លីទូទាំងប្រទេសដោយប្រើទាំងការចុះបញ្ជីជាប្រព័ន្ធ លើទ្រព្យសម្បត្តិ ទាំងទ្រព្យសម្បត្តិសាធារណៈ និង ឯកជន។ ដោះស្រាយទំនាស់ដីធ្លីតាមយន្តការដោះស្រាយទំនាស់ដីធ្លីខេត្តក្រុង។ | ជលផល ឆ្នេរ ផ្លូវទឹក និងកំណាប់រ៉ែ ឲ្យបានសមស្របតាមក្របខ័ណ្ឌច្បាប់។ អភិវឌ្ឍន៍ នីតិវិធីគ្រប់គ្រងដីធ្លីទីក្រុង និង ការតាំងលំនៅឋាន។ | ទប់ស្កាត់ការកាន់កាប់ទៅលើដីធ្លីដោយខុសទៅនឹងច្បាប់ គួបផ្សំជាមួយនិងការប្រមូលដីទុកផងដែរ។ |

គោលបំណងរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការដីធ្លីនៃតារាងខាងលើនេះ ជាមូលហេតុមួយជួយដល់ ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពជាអាទិភាពក្នុងការអនុវត្តគោលនយោបាយដីធ្លី និងជាការងារមួយដែលធ្វើឲ្យប្រសើរឡើងដល់ការយល់ដឹងជាសាធារណៈអំពីនីតិកម្មដីធ្លី។

### ១.១.៦. តម្លៃសេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

តម្លៃសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺត្រូវបានឯកភាពដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមសំណើរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ដើម្បីបញ្ជាក់ពីតម្លៃសេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ តារាងខាងក្រោមនេះនឹងបង្ហាញពីប្រភេទដី និងតម្លៃសេវា៖

តារាង២៖ តម្លៃសេវានៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធ[12]

| ប្រភេទដី | តម្លៃសេវា |
|---|---|
| ១. ដីកសិកម្ម | ១រៀល/ម$^2$ (១០០រៀលសម្រាប់ដីតូចជាង១០០ម$^2$) |
| ២. ដីលំនៅឋានជនបទ | ១០រៀល/ម$^2$ |
| ៣. ដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត | ២០រៀល/ម$^2$ |
| ៤.ដីទីប្រជុំជនខេត្ត ឬដីជាយទីប្រជុំជនក្រុងភ្នំពេញ | ៥០រៀល/ម$^2$ |
| ៥. ដីទីប្រជុំជនក្រុងភ្នំពេញ | ១០០រៀល/ម$^2$ |

តម្លៃសេវា នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅខាងលើនេះ បញ្ជាក់ឲ្យឃើញថា រាល់តម្លៃសេវាទាំងអស់ដូចជា តម្លៃសេវាលើដីកសិកម្ម តម្លៃសេវាលើដីលំនៅឋាន ជនបទ តម្លៃសេវាលើដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត តម្លៃសេវាលើដីជាយទីក្រុងភ្នំពេញ និងតម្លៃសេវាលើដីទីប្រជុំជនក្រុងភ្នំពេញ គឺមានតម្លៃសមរម្យ មិនថ្លៃពេក ក៏មិនថោកពេកដែរដែលអាចផ្តល់ជាលទ្ធភាពគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋ ក្នុងការចូលរួមដោយផ្ទាល់លើការចំណាយប្រាក់របស់ពួកគាត់ក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

## ១.២.ស្ថានភាពទូទៅនៃតំបន់ពិភាក្សាខេត្តព្រៃវែង

### ១.២.១.អំពីភូមិសាស្ត្ររបស់ខេត្តព្រៃវែង

ខេត្តព្រៃវែង ជាខេត្តមួយស្ថិតនៅទិសអាគ្នេយ៍នៃប្រទេសកម្ពុជា ដែលមានព្រំប្រទល់ខាងជើងទល់និង ខេត្តកំពង់ចាម ខាងត្បូងទល់និង ប្រទេសវៀតណាម ខាងកើតទល់និង ខេត្តស្វាយរៀង និងប្រទេសវៀតណាម ខាងលិចទល់និងខេត្តកណ្តាល។

ទន្ទឹមនឹងគ្នានេះដែរ "ខេត្តព្រៃវែងមានស្រុកចំនួន១២ដែលមានដូចជា ស្រុកពាមរក៍ ស្រុកព្រះស្តេច ស្រុកកំពង់ត្របែក ស្រុកអូរាំងឪ ស្រុកស្វាយអន្ទរ ស្រុកកញ្ជ្រៀច ស្រុកស៊ីធរកណ្តាល ស្រុកពារាំង ស្រុកកំចាយមារ ស្រុកបាភ្នំ ស្រុកមេសាង និង ស្រុកពាមជ័រ។ ខេត្តព្រៃវែងក៏មានក្រុង

[12] លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សំណើដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីតម្លៃសេវាចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ, លេខ០៥៩សហវ, ២៥ វិច្ឆិកា ២០០៣។

ចំនួន ០១ ដែលមាន ១១៣ឃុំ និង ០៣សង្កាត់ ព្រមទាំងមានប្រជាជនចំនួន ១.១៣៩.៥២៨នាក់ ភេទស្រី៥៩១.១៦៩នាក់ គិតជាគ្រួសារមាន២៩៥.៥៨៩ គ្រួសារ"[13]។

ការបង្ហាញអំពីស្ថានភាពភូមិសាស្ត្រ រួមមានស្រុក ឃុំ សង្កាត់ និង ទិន្នន័យនៃចំនួនស្ត្រីនៅខេត្តព្រៃវែងនេះ ជាប្រយោជន៍ដល់ដំណើរការ នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ព្រោះថា ដំណើររការនេះត្រូវបានបែងចែកជាច្រើនដំណាក់កាល ហើយពីមួយដំណាក់កាលទៅមួយដំណាក់កាលត្រូវការស្វែងយល់ពីស្ថានភាពដីធ្លីពីតំបន់មួយទៅតំបន់មួយ ដែលពោរពេញទៅដោយលក្ខណៈស្មុគស្មាញក្នុងការវាស់វែង ទៅតាមតំបន់វិនិច្ឆ័យដ៏ច្រើននៃស្រុកដល់ទៅចំនួន១២ នៅក្នុងខេត្តព្រៃវែងទាំងមូល ដើម្បីឈានដល់ការចែកវិញ្ញាបនបត្រដល់ប្រជាពលរដ្ឋ ធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋមានប័ណ្ណកម្មសិទ្ធិជារបស់ខ្លួនដោយស្របច្បាប់។

### ១.២.២. ស្ថានភាពទូទៅនៃស្រុកកំចាយមារ

ស្រុកកំចាយមារជាស្រុកមួយក្នុងចំណោមស្រុកទាំង១២ នៃក្រុងមួយ នៅក្នុងខេត្តព្រៃវែង ដែលស្ថិតនៅខាងកើត ឈៀងខាងជើងទីរួមខេត្ត ដែលមានចំងាយប្រហែល៩៥ គីឡូម៉ែត្រតាមបណ្តោយផ្លូវជាតិលេខ៨ ហើយជាស្រុកស្ថិតនៅជាប់ព្រំប្រទល់ប្រទេសវៀតណាម ជាហេតុបង្កលក្ខណៈងាយស្រួលដល់ប្រជាជនក្នុងការប្រកបរបរអាជីវកម្ម។

ស្រុកកំចាយមារត្រូវបានបែងចែកជា ០៨ឃុំ និង ១២៩ ភូមិ ដែលមានព្រំប្រទល់ខាងជើងទល់និងស្រុកកញ្ជៀច ខាងត្បូងទល់និងស្រុកមេសាង ខាងកើតទល់និងខេត្តស្វាយរៀង កំពង់ចាម និងខេត្តតៃនិញប្រទេសវៀតណាម ខាងត្បូងទល់និងស្រុកស្វាយអន្ទរ។ ម្យ៉ាងវិញទៀតស្រុកកំចាយមារមានឃុំចំនួន ០៨ ដែលក្នុងនោះមាន ឃុំជាច ឃុំដូនកឹង ឃុំក្រញូង ឃុំក្របៅ ឃុំស៊ាងឃ្វាង ឃុំស្មោងជើង ឃុំស្មោងត្បូង និងឃុំត្របែក។[14]

---

[13] ដូច២។

[14] បទសម្ភាសជាមួយនឹងមេភូមិនៅភូមិពោន ស្រុកកំចាយមារខេត្តព្រៃវែង, ២៦ មិថុនា ២០១៤ ។

### ១.២.៣. ប្រជាជន និងមុខរបរ

ស្រុកកំចាយមារមានប្រជាជនសរុបចំនួន៨៨៦១៥នាក់ ចែកចេញជាគ្រួសារ ១៩៦៩២ ហើយមានស្ត្រីចំនួន៤៥១៩៤នាក់ត្រូវជាភាគរយ។ ប្រជាជននៅក្នុងស្រុកនេះកាន់ព្រះពុទ្ធសាសនា ចំពោះមុខរបរប្រជាជននៅទីនោះមាន ៩០% ប្រកបរបរកសិកម្ម ២%ជាមន្ត្រីរាជការ ជាងធ្វើផ្ទះ កម្មករសំណង់ និង ធ្វើការនៅទីក្រុងជាកម្មកររោងចក្រ។[15]

ការបង្ហាញនូវសេចក្តីលម្អិតអំពីស្ថានភាពទូទៅ នៃតំបន់ពិភាក្សាខេត្តព្រៃវែង ដោយមានបែងចែកជាស្ថានភាពភូមិសាស្ត្រផ្ទាល់របស់ខេត្តព្រៃវែង ស្ថានភាពទូទៅនៃស្រុកកំចាយមារ ប្រជាជនជាមួយនឹងមុខរបររបស់ពួកគាត់ គឺជាមូលហេតុដ៏ចាំបាច់ ជាគន្លឹះក្នុងដំណាក់កាលនីមួយៗឲ្យមានដំណើរការល្អនៅក្នុងការស្វែងយល់ និង ជាការពិភាក្សាទៅលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុងតំបន់នេះផ្ទាល់។ម្យ៉ាងវិញទៀត បើគ្មានការបង្ហាញពីស្ថានភាពទាំងអស់នេះទេ ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធនៅស្រុកកំចាយមារ ខេត្តព្រៃវែងក៏មិនអាចប្រព្រឹត្តទៅបានដែរ។

[15]ដូច១៤។

# ជំពូកទី២
# ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅខេត្តព្រៃវែង

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺជាដំណើរការនៃការសាងសង់ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី តាមរយៈការកំណត់តំបន់ណាមួយជាតំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ ហើយបន្ទាប់មកចុះបញ្ជីក្បាលដីទាំងអស់នៅក្នុងតំបន់ ដែលត្រូវធ្វើការវិនិច្ឆ័យនោះចូលទៅក្នុងសៀវភៅគោលបញ្ជីដីធ្លីក្នុងលក្ខណៈជាតំបន់តែម្តង ហើយព្រមទាំងចេញនូវប័ណ្ណកម្មសិទ្ធិជាស្ថាពរជូនដល់ម្ចាស់ដី។

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះគេអាចធ្វើការ ចុះបញ្ជីក្បាលដីពីមួយតំបន់ទៅមួយតំបន់ដែលគេបានកំណត់ថាជាតំបន់វិនិច្ឆ័យរហូតទាត់តែក្បាលដីទាំងអស់ នៅទូទាំងប្រទេសត្រូវបានចុះបញ្ជីទៅក្នុងសៀវភៅគោលបញ្ជីដីធ្លីចប់សព្វគ្រប់។[16] ប៉ុន្តែការចុះបញ្ជីក្បាលដីទាំងអស់នៅទូទាំងប្រទេស ឲ្យបានចប់សព្វគ្រប់នេះ ត្រូវការចំណាយពេលវេលាជាច្រើនឆ្នាំ ព្រោះសូម្បីតែការចុះបញ្ជីក្បាលដីនៅតំបន់វិនិច្ឆ័យមួយក៏ ត្រូវចំណាយពេលវេលាយ៉ាងច្រើនដែរ។

ម្យ៉ាងវិញទៀត ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនូវក្បាលដី ទាំងអស់នៅទូទាំងប្រទេសទៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ដើម្បីបង្កើតប្រព័ន្ធចុះបញ្ជីសុរិយោដីមួយដែលអាចមានលក្ខណៈរឹងមាំ និង ទុកចិត្តបានគឺជាកិច្ចការដែលមានលក្ខណៈស្មុគស្មាញ ទាមទារនូវពេលវេលា និង មន្ត្រីដែលត្រូវអនុវត្តកិច្ចការនេះយ៉ាងច្រើន ដោយសារមូលហេតុនេះ សូមលើកយកតែតំបន់មួយក្នុងចំណោមតំបន់ជាច្រើននៅក្នុងខេត្តព្រៃវែង គឺជាតំបន់មួយស្ថិតនៅក្នុងឃុំ ស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង ដើម្បីពិភាក្សា ក៏ដូចជាស្រាយបំភ្លឺអំពីដំណើរការនីមួយៗដូចខាងក្រោម៖

## ២.១. ដំណាក់កាលត្រៀមរៀបចំ

### ២.១.១. អភិបាលខេត្តស្នើសុំក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

នៅក្នុងដំណាក់កាលដំបូង នៃដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺ បន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការជ្រើសទីតាំង

[16] អ៊ុន សក្កដា, *សៀវភៅនីតិនគរូបនីយវិទ្យា* (ភ្នំពេញ, ២០១៣)។

រួចមក គណៈអភិបាលខេត្តត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ។[17]

### ២.១.២. អភិបាលខេត្តចេញសេចក្ដីសម្រេចកំណត់តំបន់វិនិច្ឆ័យ

នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១២ "អភិបាលខេត្តព្រៃវែងបានចេញសេចក្តីសម្រេច ស្តីពីការកំណត់តំបន់សម្រាប់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋានប្រាប់អំពីការកំណត់តំបន់វិនិច្ឆ័យ"[18] ថាស្ថិតនៅមូលដ្ឋានរបស់គេដើម្បីបង្កលក្ខណៈងាយស្រួល និងចូលរួមសហការនៅក្នុងកិច្ចការនោះ។ ជាមួយគ្នានេះដែរ "នៅក្នុងការកំណត់តំបន់វិនិច្ឆ័យនេះគណៈអភិបាលខេត្តក្រុងត្រូវធ្វើលិខិតជាផ្លូវការដែលពិពណ៌នា និង អនុញ្ញាតឲ្យអនុម័តនីតិវិធីនៃការវិនិច្ឆ័យដីធ្លីមានលក្ខណៈជាប្រព័ន្ធទៅអាជ្ញាធរ នៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងហោចណាស់ ១៥ថ្ងៃមុនកិច្ចប្រជុំផ្សព្វផ្សាយ និង ព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ"[19]។

### ២.១.៣. អភិបាលខេត្តចេញសេចក្ដីសម្រេចបង្កើតគណៈកម្មការ

អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង បានចេញសេចក្តីសម្រេចមួយទៀត គឺជាសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការរដ្ឋបាល នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យសម្រាប់នីតិវិធី នៃការកសាង ប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី។ តារាងខាងក្រោមនេះនឹងបញ្ជាក់អំពីសមាសភាព មុខងារ ភារកិច្ច សិទ្ធិនៃការកំណត់របស់គណៈកម្មការរដ្ឋបាលដីធ្លីក្នុងតំបន់វិនិច្ឆ័យឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង៖

---

17 សារាចរណែនាំអនុវត្តន៍នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធលេខ ០០១ដសន/សជ, ១៩ សីហា ២០០២។

18 សេចក្តីសម្រេចស្តីពីការកំណត់តំបន់សម្រាប់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ, លេខ០០៤/១២សសរ, ១៣ មករា ២០១២។

19 ដូច១៧ ។

តារាង៣៖ សមាសភាព មុខងារ សិទ្ធិនិងភារកិច្ចរបស់គណៈកម្មការរដ្ឋបាល[20]

| សមាសភាព | មុខងារ |
|---|---|
| អភិបាលរងនៃគណៈអភិបាលខេត្ត | ប្រធាន |
| អភិបាលនៃគណៈអភិបាលស្រុកកំចាយមារ | សមាជិក |
| មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ | សមាជិក |
| មេឃុំស្មោងជើង និង មេភូមិពោន | សមាជិក |
| ចាស់ព្រឹទ្ធាចារ្យភូមិពោន (២នាក់) | សមាជិក |

| **ភារកិច្ច និង សិទ្ធិ** |
|---|
| – ជាសេនាធិការឲ្យក្រសួងរៀបចំដែនដី ក្នុងការតាមដានត្រួតពិនិត្យក្នុងតំបន់វិនិច្ឆ័យ<br>– រៀបចំការផ្សព្វផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យ<br>– ទទួលរាល់ការប្រឆាំងជំទាស់លើឯកសារវិនិច្ឆ័យ<br>– ទទួលធ្វើការសម្រុះសម្រួលវិវាទផ្សេងៗដែលកើតមានក្នុងតំបន់វិនិច្ឆ័យ<br>– មានសិទ្ធិចុះហត្ថលេខាបញ្ជាក់ថា ឯកសារមានលក្ខណៈត្រឹមត្រូវ និងស្របច្បាប់<br>– លើកសំណើផ្តល់សិទ្ធិលើដីធ្លី ជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាសម្បត្តិរដ្ឋ |

តាមរយៈតារាងខាងលើនេះ បង្ហាញអំពីការបង្កើតឲ្យមានគណៈកម្មការរដ្ឋបាល ក្នុងតំបន់ធ្វើការវិនិច្ឆ័យនៅឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង គឺបង្កើតឡើងដើម្បីធានាដល់ការ

[20]សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការរដ្ឋបាលក្នុងតំបន់ធ្វើការវិនិច្ឆ័យសម្រាប់នៅនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ០០៧/១២សសរ, ១៨ មករា ២០១២។

កសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឲ្យឈានទៅដល់ការគ្រប់គ្រងទៅលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធឲ្យបានសម្រេចជាស្ថាពរ។

### ២.១.៤. កិច្ចប្រជុំពិភាក្សាកំណត់ព្រំប្រទល់

កិច្ចប្រជុំពិភាក្សាកំណត់ព្រំប្រទល់ត្រូវបានធ្វើឡើងនៅវេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសាលាឃុំស្មោងជើងដោយមានការចូលរួមពីមេឃុំស្មោងជើង មេភូមិ និងមន្ត្រីជំនាញនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី។ កិច្ចប្រជុំនេះចាំបាច់ណាស់ត្រូវតែធ្វើ ដើម្បីកំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់ត្រឹមត្រូវជាមុន មុននឹងប្រកាសកំណត់តំបន់វិនិច្ឆ័យ។ ជាមួយគ្នានេះដែរកិច្ចប្រជុំនេះគឺតម្រូវឲ្យមេភូមិ មន្ត្រីជំនាញ មន្ត្រីទាំងអស់ ជាពិសេសមន្ត្រីកំណត់ព្រំសហការគ្នា យកចិត្តទុកដាក់ជៀសវាងការកំណត់ព្រំប្រទល់ខុសលើដីជាក់ស្តែង។ ជាលទ្ធផលការប្រជុំត្រូវបានបញ្ចប់ដោយមានការឯកភាពគ្នាទៅវិញទៅមកលើព្រំប្រទល់រវាងឃុំស្មោងជើងទៅនិងឃុំព្រាល ឃុំដូនកឹង ឃុំក្រញ៉ូង ឃុំអណ្តូងត្របែក ឃុំស្មោងត្បូង ឃុំពានរោង និងឃុំទទឹង។[21]

បន្ទាប់ពីកិច្ចប្រជុំពិភាក្សាកំណត់ព្រំប្រទល់ត្រូវបានបញ្ចប់ អភិបាលនៃគណៈអភិបាលខេត្តបានចេញសេចក្តីសម្រេចកំណត់តំបន់ក្នុងឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង ជាតំបន់វិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ។[22]

សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង ដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាន អគ្គនាយកដ្ឋានសុរិយោដីភូមិសាស្ត្រ ខុទ្ទការល័យសាលាខេត្ត អគ្គលេខាធិការសាលាខេត្ត សាលាស្រុកកំចាយមារ សាលាឃុំស្មោងជើង ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងក្បាលដីស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ មន្ត្រីជំនាញសុរិយោដីឲ្យមានប្រសិទ្ធភាព។[23]

---

[21] គង់ អ៊ន់, *កំណត់ហេតុស្តីពីកិច្ចប្រជុំពិភាក្សាកំណត់ព្រំប្រទល់រដ្ឋបាលរវាងឃុំស្មោងជើង និងឃុំដទៃទៀត*, ២៤ កុម្ភៈ ២០១២។

[22]ដូច១៨, ប្រការ១។

[23]ដូច១៨, ប្រការ២ និង៣។

### ២.១.៥. កិច្ចប្រជុំបើកវគ្គបណ្តុះបណ្តាល

បន្ទាប់ពីបានបង្កើតគណៈកម្មការរដ្ឋបាល ដោយមានបង្ហាញជាតារាងសម្រាប់ជំនួយកំណត់អំពី ឈ្មោះ សមាសភាព មុខងារ និង មានការបែងចែកអំពីសិទ្ធិ ភារកិច្ចរបស់គណៈកម្មការទាំងអស់នៅក្នុងចំណុច២.១ និង ចំណុច២.១.៣រួចមក គឺ នាយកចាត់ការកម្មវិធីខេត្តព្រៃវែង បានធ្វើសំណើសុំបើកកិច្ចប្រជុំបើក វគ្គបណ្តុះបណ្តាលគណៈកម្មការរដ្ឋបាលដីធ្លី និង ផ្តល់គ្រូបណ្តុះបណ្តាល សំភារៈ ថវិកា ស្នើទៅឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋាន និង ភូមិសាស្ត្រ ។ ការស្នើសុំនេះ ដើម្បីជាប្រយោជន៍ ដើម្បីផ្តល់នូវចំណេះដឹងយ៉ាងទូលំទូលាយដូចជាជួយពន្យល់ឲ្យមេឃុំ មេភូមិ យល់ពីដំណាក់កាលទាំង៥លើប្រព័ន្ធចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធនៅក្នុងតំបន់នៃឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែងឲ្យបានច្បាស់លាស់ដោយមានជាឯកសារពាក់ព័ន្ធក៏ដូចជាដោះស្រាយនូវចម្ងល់ផ្សេងៗដែលមេភូមិ មេឃុំពុំទាន់យល់ច្បាស់ប្រកបទៅដោយប្រសិទ្ធភាពបំផុត។[24] ជាលទ្ធផលនាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីខេត្តព្រៃវែងក៏បានយល់ព្រម លើការបើកវគ្គបណ្តុះបណ្តាលគណៈកម្មការរដ្ឋបាលឃុំ ស្មោងជើងស្រុកកំចាយមារ ដែលមានរយៈពេលយ៉ាងតិចមួយខែ។

រាល់ជំហាននីមួយៗនៃដំណាក់កាលទី១ដែលបានលើកឡើងនៅខាងលើនេះ ពុំមានចោទជាបញ្ហាធ្ងន់ធ្ងរអ្វីនោះទេ គឺគ្រាន់តែមានដំណើរការយឺតយាវ ទៅលើពេលវេលាបន្តិចបន្តួចប៉ុណ្ណោះ ចំណុចសំខាន់គឺ រាល់ជំហាននីមួយៗត្រូវបានធ្វើឡើងយ៉ាងម៉ត់ចត់ និង យកចិត្តទុកដាក់ជាទីបំផុតទាំងអភិបាលខេត្ត មេភូមិ មេឃុំ និង គណៈកម្មការរដ្ឋបាលទាំងអស់។

## ២.២. ដំណាក់កាលប្រតិបត្តិការបច្ចេកទេស

យោងទៅតាមខ្លឹមសារអនុក្រឹត្យលេខ ៤៦ និង សារាចរលេខ ០១ មន្ត្រីនៃក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបែងចែកទៅតាមផ្នែក និងតាមជំនាញដូចជាៈ មន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង មន្ត្រីវិនិច្ឆ័យ និងមន្ត្រីការិយាល័យ ហើយដែលស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យ ទាំងផ្នែកបច្ចេកទេស ទាំងផ្នែកច្បាប់ របស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យក្នុងការអនុវត្ត

[24] សំណើបើកវគ្គបណ្តុះបណ្តាលគណៈកម្មការរដ្ឋបាលដល់ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋាន និង ភូមិសាស្ត្រ និង ជានាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី, លេខ ៤៥/១២, ១២ មីនា ២០១២។

ដោយមានការសហការ និងជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន (មេភូមិ មេឃុំ ឬចៅសង្កាត់) ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ មានភារកិច្ចត្រួតពិនិត្យលើភាពត្រឹមត្រូវ លើការងារបច្ចេកទេស និង ច្បាប់ក្នុងការវាស់វែង និង ការបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងសម្របសម្រួលការងារជាមួយអាជ្ញាធរមូលដ្ឋាន។

ដំណាក់កាលប្រតិបត្តិការបច្ចេកទេសនេះ គឺជាដំណាក់កាលទី២ នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងជាដំណាក់កាលមួយដែលត្រូវបានបែងចែកជាពីរជំហាន ជំហានទី១ គឺតម្រូវទៅលើការងារនៅវាល ជំហានទី២តម្រូវទៅលើការងារនៅការិយាល័យ។[25] លើសពីនេះទៅទៀត ជំហានទាំងពីរនេះ បង្កប់ទៅដោយការងារត្រូវប្រើប្រាស់បច្ចេកទេសជាច្រើនជាចាំបាច់ដូចជា៖

### ២.២.១. ការងារវាល

ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីកំណត់ព្រំ មន្ត្រីវាស់វែង និង មន្ត្រីវិនិច្ឆ័យ ដោយមានការសហការ និងការជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន មេភូមិ មេឃុំ។ ម្យ៉ាងវិញទៀតមន្ត្រីទាំងបីនេះមានការងារជាច្រើនដែលត្រូវបំពេញ រួមទាំងការងារបច្ចេកទេសដែលពិបាកៗត្រូវធ្វើដូចខាងក្រោម:

#### ២.២.១.១. ការកំណត់ព្រំដី

ការកំណត់ព្រំដី គឺជាការកំណត់ជាក់ស្តែងនៅលើដីនូវព្រំនៃក្បាលដី ព្រមទាំងព្រំប្រទល់រដ្ឋបាលខេត្ត ស្រុក ភូមិ ឃុំ និងសេរភាពជាដើម។ ការកំណត់ព្រំដីត្រូវធ្វើឡើងដោយមន្ត្រីកំណត់ព្រំនៅចំពោះមុខម្ចាស់នៃក្បាលដី និងម្ចាស់ក្បាលដីទាំងឡាយដែលមានព្រំជាប់ក្នុងពេលដំណាលគ្នាជា មួយដំណើរការនៃការវិនិច្ឆ័យ។ ការកំណត់ព្រំដីនេះរួមបញ្ចូលទាំងការរៀបចំឯកសារ និងការធ្វើគំនូសព្រៀង ការបោះបង្គោលព្រំដីដែលបង្ហាញលើប្លង់សុរិយោដីបាន។[26]

[25] ដូច១៧។

[26] បទសម្ភាសជាមួយនឹងមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តព្រៃវែង(ទទួលបន្ទុកគ្រប់គ្រងតំបន់វិនិច្ឆ័យ ស្រុកកំចាយមារ ខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន (២៦ ឧសភា ២០១៤)។

### ២.២.១.២. ការវាស់វែង

បន្ទាប់ពីបានកំណត់ព្រំដីរួចមន្ត្រីវាស់វែងត្រូវអនុវត្តការងារ ដោយរៀបចំសំភារៈវាស់វែង និង ប្រមូលទិន្នន័យពីវាលជាមុននៅក្នុងតំបន់វិនិច្ឆ័យ ផែនការនេះនិងធ្វើឲ្យសម្រេចបាននូវការវាស់វែងដី ដែលជាតម្រូវការចាំបាច់ក្នុងការកសាងប្លង់សុរិយោដី និង ការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ។[27]

### ២.២.១.៣. ការវិនិច្ឆ័យ

ការវិនិច្ឆ័យជាដំណើរការមួយ ដែលអាចធ្វើការកំណត់នូវសិទ្ធិដែលមានលើក្បាលដីមានលក្ខណៈជាផ្លូវការ ដោយមិនកែប្រែសិទ្ធិដែលមាននៅលើក្បាលដី ឬ បង្កើតសិទ្ធិថ្មីឡើយ។ ព្រមទាំងអង្កេតរាល់ឯកសារ និង ពិតមានផ្សេងៗជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់វិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះចូលទៅក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។ លទ្ធផលនៃការវិនិច្ឆ័យ គឺជាបញ្ជីដីធ្លីមួយ ដែលមានលក្ខណៈពេញលេញច្បាស់លាស់ និងស្ថាពរតាមផ្លូវច្បាប់ដែលជាភស្តុតាងរឹងមាំនៃសិទ្ធិ ដែលមានការធានាដោយរដ្ឋតាមមធ្យោបាយច្បាប់។[28]

នៅក្នុងផ្នែកនៃការកំណត់ព្រំដី ការវាស់វែង ការវិនិច្ឆ័យ ជាការសម្ភាសផ្ទាល់ពីមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ ស្រុកកំចាយមារ។ តទៅខាងក្រោមនេះនឹងមានតារាងជាការបង្ហាញលម្អិតអំពីសិទ្ធិ និងភារកិច្ច ហើយនៅក្នុងតារាងត្រូវបានបែងចែកបន្តពីតារាងខាងលើ ជាប្រយោជន៍បង្កលក្ខណៈងាយស្រួលមើល ងាយចងចាំ ធ្វើឲ្យអ្នកអានងាយស្វែងយល់ និងដើម្បីយកទៅប្រើប្រាស់ក្នុងស្ថានភាពតម្រូវក្នុងការសិក្សាផងដែរ។

ជាថ្មីម្តងទៀតតារាងដែលត្រូវបែងចែកនោះរួមមាន តារាងទី៤បង្ហាញពីសិទ្ធិ និងភារកិច្ចរបស់មន្ត្រីកំណត់ព្រំដី និង មន្ត្រីវិនិច្ឆ័យ តារាងទី៥បង្ហាញពីសិទ្ធិ និងភារកិច្ចរបស់អ្នកកាន់កាប់ដី និងបង្ហាញអំពីសិទ្ធិ និងភារកិច្ចរបស់អាជ្ញាធរដែនដី៖

[27] ដូច២៦ ។

[28]ដូច២៦ ។

## តារាង៨៖ សិទ្ធិ និងភារកិច្ចមន្ត្រីកំណត់ព្រំដី និង មន្ត្រីវិនិច្ឆ័យ[29]

| មន្ត្រីកំណត់ព្រំដី | មន្ត្រីវិនិច្ឆ័យ |
|---|---|
| មន្ត្រីកំណត់ព្រំដី ត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ ធ្វើការវិនិច្ឆ័យ រៀបចំពេលវេលានិងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឲ្យបានមុន ៧ថ្ងៃយ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឲ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន ទៅតាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង។កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំប្រសិនបើមន្ត្រីគ្រប់គ្រងការងារវិនិច្ឆ័យឬអាជ្ញាធរ មូលដ្ឋានចាត់ទុកថាជាការចាំបាច់។<br>បើកម្មសិទ្ធិករ ឬ ម្ចាស់នៃក្បាលដីនិងម្ចាស់នៃក្បាលដីដែលជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង។ បើការព្រមព្រៀង មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករឬម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្ត មាន នោះព្រំប្រទល់នោះត្រូវកំណត់លើដី តាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី | មានសិទ្ធិសាកសួរយកពត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យអាចអញ្ជើញជនដែលពាក់ព័ន្ធឲ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬ ភស្តុតាងផ្សេងៗទាក់ទងទៅនឹងការវិនិច្ឆ័យ។<br>ត្រូវអង្កេតរាល់ឯកសារភស្តុតាងនិងពត៌មានផ្សេងៗជាលាយ លក្ខណ៍អក្សរ ឬផ្ទាល់មាត់ទាក់ទងទៅនិងសិទ្ធិលើក្បាលដីនីមួយៗ។<br>មន្ត្រីវិនិច្ឆ័យមានសិទ្ធិក្នុងការសន្និដ្ឋាន វាយតម្លៃកំណត់សិទ្ធិច្បាស់លាស់ចំពោះម្ចាស់អចលនវត្ថុ។<br>កត់ត្រាសិទ្ធិទាំងនេះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និង ស្នើឲ្យមន្ត្រីវិនិច្ឆ័យ ជាអ្នកទទួលខុសត្រូវលើពត៌មានដែលខ្លួនបានធ្វើការវិនិច្ឆ័យលើក្បាលដីនីមួយៗ។ |

[29] ដូច១៧។

តារាង៥៖ សិទ្ធិ និងភារកិច្ចអ្នកកាន់កាប់ដី និង អាជ្ញាធរដែនដី[30]

| អ្នកកាន់កាប់ដី | អាជ្ញាធរដែនដី |
|---|---|
| អ្នកកាន់កាប់ដី ឬអ្នកតំណាងដោយស្របច្បាប់ មានកាតព្វកិច្ចចូលរួម និង សហការក្នុងការកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យតាមរយៈការផ្តល់នូវព័តមានពិត ឬ ដោយផ្ទាល់មាត់ជាលាយលក្ខណ៍អក្សរ ឬ ភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬ ក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬ ក្បាលដីអ្នកជាប់ព្រំដល់មន្ត្រីជំនាញ។<br>ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់ឬ ជនពាក់ព័ន្ធមានសិទ្ធិជំទាស់ ឬតវ៉ា ប្រសិនបើខ្លួនយល់ថាទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យនោះ មិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន។ | អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបង្កលក្ខណៈសម្បត្តិងាយស្រួល សហការឲ្យបានល្អ និង ផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការទាំងឡាយ មានប្រតិបត្តិការបច្ចេកទេស រដ្ឋបាលគតិយុត្ត ដើម្បីធ្វើឲ្យសម្រេចនូវការអនុវត្តនីតិវិធី នៃការវិនិច្ឆ័យដែលប្រព្រឹត្តទៅនៅក្នុងដែនដីដែលខ្លួនទទួលខុសត្រូវ។<br>ក្នុងរយៈពេល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារ នៃការវិនិច្ឆ័យ ដែលមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីក្នុងឃុំ មេឃុំ ឬតំណាងស្របច្បាប់របស់ខ្លួនត្រូវមានវត្តមានតាមកាលកំណត់ និង តាមតម្រូវការជាក់ស្តែងនៃការងារ។ |

នៅក្នុងតារាងខាងលើនេះ បង្ហាញពីការលើកឡើងពីការសម្ភាស សេចក្តីលម្អិតអំពីមន្ត្រីវិនិច្ឆ័យ មន្ត្រីកំណត់ព្រំ មន្ត្រីវាស់វែង អ្នកកាន់កាប់ដី និងអាជ្ញាធរដែនដី ជាករណីមួយដែលរាល់មន្ត្រីគ្រប់រូបត្រូវបំពេញទៅតាមជំនាញ និងតួនាទីរបស់ខ្លួន។ ម្យ៉ាងវិញទៀតមន្ត្រីជំនាញទាំងនោះគឺពួកគាត់រីករាយសប្បាយចិត្តបើទោះបីជាត្រូវស្ថិតនៅក្រោមកំដៅថ្ងៃក្តៅខ្លាំង ឬជួនពេលខ្លះមានភ្លៀងបង្កផលវិបាកប៉ុណ្ណាក៏ដោយ ព្រោះតែពួកគាត់គិតថា ជាការងារលើដីធ្លីរបស់ប្រជាជនខ្មែរ ហើយរូបគាត់ក៏ជាខ្មែរដូចគ្នា ដើម្បីឲ្យការរៀបចំដែនដីនៃប្រទេសកម្ពុជា ជាពិសេសការចុះបញ្ជីដីធ្លី

[30] ដូច១៧។

មានលក្ខណៈជាប្រព័ន្ធ លើដំណាក់កាលនីមួយៗដោយរលូន និងមានប័ណ្ណកម្មសិទ្ធិ និងវិញ្ញាបនបត្រគ្រប់ៗគ្នា។

### ២.២.២. ការងារការិយាល័យ

រាល់ទិន្នន័យដែលប្រមូលបានពីការងារវាល ជាចាំបាច់ត្រូវបញ្ចូលក្នុងកុំព្យូទ័រដើម្បីកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី ព្រមទាំងរៀបចំចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដល់ម្ចាស់ដី។

តារាងខាងក្រោមនេះ ជាទិន្នន័យត្រួតពិនិត្យគុណភាពក្បាលដីរបស់ប្រធានក្រុមត្រួតពិនិត្យគុណភាពក្បាលដី នៅភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង៖

តារាង៦៖ ទិន្នន័យត្រួតពិនិត្យគុណភាពក្បាលដី[31]

| ការងារវាល និង ការងារការិយាល័យ | ចំនួនក្បាលដីដែលបានត្រួតពិនិត្យចំនួន៤៥ក្បាលដី |
|---|---|
| ១. ការងារវិនិច្ឆ័យ | – គ្រប់គ្រាន់ចំនួន ៣៥ ក្បាលដី<br>– មិនគ្រប់គ្រាន់ចំនួន ១០ក្បាលដី |
| ២.ការងារវាស់វែង និងកំណត់ព្រំ | – ត្រឹមត្រូវចំនួន ៤៥ ក្បាលដី<br>– លំអៀងលើសកំហុសអនុញ្ញាត ០០ ក្បាលដី |
| ៣. ការងារបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ | – ត្រឹមត្រូវចំនួន ៤៤ ក្បាលដី<br>– មិនត្រឹមត្រូវចំនួន ០១ ក្បាលដី |

តារាងខាងលើនេះបានបង្ហាញឲ្យឃើញថា ការងារវិនិច្ឆ័យនៅភូមិនេះមិនត្រឹមត្រូវចំនួន ១០ ក្បាលដី ចំណែកការងារក្នុងកុំព្យូទ័រវិញ មិនត្រឹមត្រូវ ០១ ក្បាលដី។ ទាំងនេះបញ្ជាក់ថាមានបញ្ហាលើការងារវិនិច្ឆ័យ ព្រោះមន្ត្រីវិនិច្ឆ័យធ្វើការវិនិច្ឆ័យមិនត្រឹមត្រូវដល់ទៅ ១០ក្បាលដី។ ប៉ុន្តែបញ្ហានេះត្រូវបានដោះស្រាយដោយការត្រួតពិនិត្យ និង អនុវត្តនូវការងារនេះឡើងវិញ យ៉ាងយកចិត្តទុកដាក់បំផុតពីប្រធានក្រុមត្រួតពិនិត្យគុណភាពក្បាលដី ។

បន្ទាប់ពីធ្វើការស្វែងយល់ពី ការងារនៅវាល និង ការងារនៅការិយាល័យដែលបានលើកឡើងខាងលើនេះរួចមក ក៏បានរកឃើញនូវបញ្ហាលំបាកៗខ្លះមួយចំនួនទៀត ដែលបានកើតឡើង

[31] ស៊ាន យុន្នី, លិខិតជូនលោកនាយកចាត់ការគម្រោងខេត្តស្តីពីលទ្ធផលនៃការចុះពិនិត្យគុណភាពក្បាលដី, ២៩ មេសា ២០១៣។

ក្នុងស្ថានភាពជាក់ស្តែងនៅឃុំស្មោងជើង ស្រុកកំចាយមារ នៃការគ្រប់គ្រងលើការងារទាំងពីរនេះដូចការកំណត់ក្នុងតារាងខាងក្រោម៖

តារាង៧៖ បញ្ហាលើការងារនៅវាល និងនៅការិយាល័យ

| អត្ថន័យ[32] | បញ្ហា[33] |
|---|---|
| ១.ការប្រមូលទិន្នន័យៈ រាល់ទិន្នន័យទាំងអស់ដែលទាក់ទងទៅនឹងក្បាលដីនីមួយៗ ត្រូវកត់ត្រាបញ្ចូលទៅក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។ | ម្ចាស់ដីខ្លះពុំបានចូលរួមទាន់ពេលវេលាក្នុងការកំណត់ព្រំ និង វិនិច្ឆ័យ នាំឲ្យយឺតយាវដល់ការប្រមូលទិន្នន័យ។ |
| ២.អត្តសញ្ញាណនៃម្ចាស់អចលនវត្ថុៈចំពោះរូបវន្តបុគ្គលគឺត្រូវកត់ត្រា ឈ្មោះ ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើត សញ្ជាតិ ឈ្មោះឪពុកម្តាយ ទីលំនៅឋានជាដើម។ | បង្កឲ្យមានភាពយឺតយាវក្នុងការបំពេញទិន្នន័យក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីដោយសារតែម្ចាស់ដីមួយចំនួនធំមិនទាន់មានអត្តសញ្ញាណប័ណ្ណគ្រប់គ្រាន់ ខ្វះសារតាឪពុកម្តាយ។ |
| ៣.សិទ្ធិលើអចលនវត្ថុៈ សំដៅទៅលើប្រភេទទ្រព្យប្តីប្រពន្ធ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ | ធ្វើឲ្យលំបាកក្នុងការកំណត់សិទ្ធិព្រោះគ្រួសារមួយចំនួនលែងលះ ឬ ចុះចោលដោយពុំមានការបញ្ជាក់ច្បាស់លាស់។ |
| ៤.ច្បាប់ និង សិទ្ធិ | ពុំមានច្បាប់កំណត់អំពីដីចំណីអូរ ប្រឡាយ ផ្លូវលំ ជាពិសេសជាហេតុនាំឲ្យមានការស្ទាក់ស្ទើរក្នុងការរក្សាទុក ឬ ប្រគល់សិទ្ធិឲ្យឯកជន។ |
| ៥.ព្រំប្រទល់ | ភូមិសាស្ត្រសំបូរព្រៃដែលជាហេតុនាំឲ្យមានការលំបាកក្នុងការកំណត់ព្រំប្រទល់។ |

តាមរយៈតារាងខាងលើនេះ បង្ហាញឲ្យឃើញពីបញ្ហាមួយចំនួនដែលកើតឡើងហើយផ្តល់ជា ផលវិបាកដល់មន្ត្រីវិនិច្ឆ័យក្នុងការប្រមូលទិន្នន័យក្បាលដី អត្តសញ្ញាណនៃម្ចាស់អចលនវត្ថុ និងការផ្តល់សិទ្ធិលើដីធ្លីដល់ម្ចាស់ដី។

[32] ដូច២៦។

[33] កែវ សេន, *របាយការណ៍បូកសរុបការអនុវត្តន៍នីតិវិធីនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ*, លេខ៣០៩ (ព្រៃវែង៖ ១៤ មិថុនា ២០១៣)។

ទន្ទឹមនិងការជួបប្រទះនូវផលវិបាកយ៉ាងណាក៏ដោយ ក៏រាល់មន្ត្រីជំនាញទាំងអស់នៅតែអាចដោះស្រាយបញ្ហាបានជូនដល់ប្រជាពលរដ្ឋ។ ម្យ៉ាងវិញទៀតនៅក្នុងដំណាក់ការទី២នេះផងដែរ រាល់មន្ត្រីទាំងអស់ នៅក្នុងមន្ទីរសុរិយោដីខេត្តក្រុងសុទ្ធសឹងតែបានទទួលការរៀន បើកវគ្គបណ្ដុះបណ្ដាល ពីកម្មវិធីបង្រៀនណែនាំឲ្យចេះ យល់ច្បាស់ទៅលើការយល់ដឹងជាសាធារណៈ និងការចូលរួមពីសហគមន៍ និងការរៀបចំដែនដី ផ្នែកទូទៅរបស់ PACP-LM គោលបំណងរបស់ PACM-LM តួនាទី និងភារកិច្ចរបស់មន្ត្រីផ្សព្វផ្សាយ និងរៀបចំដែនដី ចំណាត់ថ្នាក់ដី តម្លៃសេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ភារកិច្ចរបស់មន្ត្រីរៀបចំដែនដី សុពលភាពនៃពត៌មានដែលប្រមូលបានលើរូបថត មធ្យោបាយនៃការផ្សព្វផ្សាយធ្វើយ៉ាងណាឲ្យការអនុវត្តនេះប្រព្រឹត្តទៅបានល្អប្រសើរដល់ដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ។

## ២.៣. ដំណាក់កាលការបិទផ្សាយជាសាធារណៈ

ការបិទផ្សាយជាសាធារណៈ គឺជាដំណើរការមួយដែលនៅក្នុងនោះឯកសារនៃការវិនិច្ឆ័យ (ប្លង់សុរិយោដី និង បញ្ជីឈ្មោះអ្នកកាន់កាប់ដី) ត្រូវគេបិទផ្សាយដល់សាធារណៈជនដើម្បីឲ្យភាគីដែលមានផលប្រយោជន៍អាចស្នើការកែតម្រូវ ឬដាក់ពាក្យបណ្ដឹងតវ៉ាចំពោះទិន្នន័យនោះ។

ជាគោលការណ៍ មិនថាតំបន់ណាមួយ ឬស្ថិតនៅក្នុងខេត្តណាមួយឡើយឲ្យតែជាខេត្តដែលស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយស្ថិតនៅក្នុងគម្រោង ដែលត្រូវចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ តែងតែមានការបូកសរុបនូវចំនួនក្បាលដីមុនពេលធ្វើការបិទផ្សាយ។ ដូចគ្នានេះដែរតារាងខាងក្រោមនេះ នឹងបញ្ជាក់ពីទិន្នន័យក្បាលដីមុនពេលបិទផ្សាយនៅភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែងដែលរួមមានប្រភេទដី និងចំនួនក្បាលដីដូចខាងក្រោម៖

តារាង៨៖ លទ្ធផលបូកសរុបក្បាលដីមុនពេលបិទផ្សាយ[34]

| ប្រភេទដី | ចំនួនក្បាលដី |
|---|---|
| ដីសាងសង់ | ១៥៣ |
| ចំនួនក្បាលដីមិនចេញប័ណ្ណទាំងដីសាងសង់និង ដីកសិកម្ម | ៨៨៦ |
| ដីកសិកម្ម | ៨ |

[34] ហេង ហួរ, *រូបភាពប្រើប្រាស់ក្បាលដីមុនពេលបិទផ្សាយនៅភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង*, ២០១៣។

| | |
|---|---|
| ប្តូរប្រភេទដី ពីកសិកម្ម ទៅដីលំនៅឋាន | ៣ |
| បំបែកក្បាលដីថ្មីទាំងដីសាងសង់ និង ដីកសិកម្ម | ៥០ |
| ម្ចាស់ដីអវត្តមាន ទៅលើដីកសិកម្ម | ៥០ |
| ចំនួនក្បាលដីត្រូវចេញប័ណ្ណក្នុងនោះមានដីសាងសង់ ដីកសិកម្ម | ១៥៣ និង ៨៣៦ |

តាមរយៈតារាងខាងលើ បង្ហាញពីការស្វែងរក និង កំណត់ចំនួនទិន្នន័យក្បាលដី នៅភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ មុនពេលបិទផ្សាយជាសាធារណៈ ជាប្រយោជន៍ក្នុងការត្រួតពិនិត្យ ការប្រៀបធៀប និងកំណត់ប្រភេទដីក៏ដូចជាទិន្នន័យក្បាលដីក្នុងដំណាក់កាលនីមួយៗ នៃការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ និងមានភាពងាយស្រួលក្នុងការវិនិច្ឆ័យលើទិន្នន័យក្បាលដីបានប្រាកដប្រជា ជូនដល់ប្រជាពលរដ្ឋមានទំនុកចិត្ត និងផ្តល់ភាពជឿជាក់ថាក្បាលដីរបស់ពួកគេពិតជាត្រឹមត្រូវតាមផ្លូវច្បាប់ឥតក្លែងបន្លំឡើយ។

លើសពីនេះទៅទៀត ការបិទផ្សាយជាសាធារណៈនូវទិន្នន័យនៃការវិនិច្ឆ័យ បង្កើតឡើងយ៉ាងស្របច្បាប់នូវទិន្នន័យដែលនឹងត្រូវបាន ចុះបញ្ជីយ៉ាងមានតម្លាភាពដែលមិនអាចតវ៉ាទៀតបាន និងសុពលភាពផ្នែកច្បាប់ជាស្ថាពរ ទៅតាមបទបញ្ញាត្តច្បាប់ទាក់ទងទៅនឹង ដំណើរការនៃការបិទផ្សាយជាសាធារណៈ។

### ២.៣.១. យុទ្ធនាការផ្សព្វផ្សាយ

នៅក្នុងដំណាក់កាលនេះ អភិបាលនៃគណៈអភិបាលខេត្តបានធ្វើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីតាមសំណើរបស់គណៈកម្មការរដ្ឋបាល ម្យ៉ាងទៀតការជូនដំណឹងនេះ គឺអាចធ្វើតាមគ្រប់មធ្យោបាយដូចជា តាមរយៈការប្រជុំ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រូបភាពបិទផ្សាយ ឬតាមឧឃ្លោសនស័ន្ទ។[35]

### ២.៣.២. រយៈពេលនៃការផ្សព្វផ្សាយ

ការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដីត្រូវបានបិទក្នុងរយៈពេល៣០ថ្ងៃ ហើយក៏ត្រូវបានធ្វើឡើងនៅកន្លែងដែលងាយមើលឃើញ។ ជាមួយគ្នានេះដែរក្នុង

[35] សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ, លេខ២៤៦/១៣ សជណ, ២៥ មេសា ២០១៣។

ស្ថានភាពជាក់ស្តែង ការបិទផ្សាយនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវបានបិទផ្សាយនៅស្នាក់ការភូមិ ពោន ឃុំស្មោងជើង ស្រុកកំចាយមារ។[36]

### ២.៣.៣. ឯកសារតម្រូវ

ឯកសារតម្រូវក្នុងការបិទផ្សាយជាសាធារណៈនូវទិន្នន័យនៃការវិនិច្ឆ័យរួមមាន ប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដី។ ទន្ទឹមនឹងគ្នានេះផងដែរប្លង់សុរិយោដី ជាសន្លឹកប្លង់ដែលបង្ហាញនូវរាល់ក្បាលដីទាំងអស់ដែលមានព្រំប្រទល់ និងលេខក្បាលដី រីឯបញ្ជីឈ្មោះម្ចាស់ដី គឺជាបញ្ជីដែលផ្ទុកនូវរាល់ទិន្នន័យក្បាលដីដែលមាននៅក្នុងទម្រង់បែបបទ នៃការប្រមូលទិន្នន័យក្បាលដីដែលត្រូវបានកត់ត្រា ដោយមន្ត្រីវិនិច្ឆ័យចំពោះក្បាលដីក្នុងតំបន់វិនិច្ឆ័យ។[37]

### ២.៣.៤. ភារកិច្ច និង ទំនួលខុសត្រូវរបស់មន្ត្រីវិនិច្ឆ័យ

គួរបញ្ជាក់ផងដែរថា "ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈនេះ មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យត្រូវណែនាំមន្ត្រី ដែលទទួលខុសត្រូវការងារជំនាញនីមួយៗរបស់ខ្លួន ឲ្យប្រចាំការនៅកន្លែងបិទផ្សាយរៀងរាល់ថ្ងៃ ទាំងថ្ងៃឈប់សំរាកទាំងថ្ងៃបុណ្យផ្សេងៗ ដើម្បីរង់ចាំពន្យល់ ឬ បំភ្លឺខ្លឹមសារនៃទិន្នន័យ បកស្រាយចម្ងល់ផ្សេងៗដែលទាក់ទងទៅនឹងឯកសារដែលបានបិទផ្សាយ។ ទន្ទឹមនិងនេះ គណៈកម្មការរដ្ឋបាលក៏ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ និង មន្ត្រីនៅមូលដ្ឋានចាំបាច់ជាអាទ៏មេឃុំ ឬតំណាងផ្លូវច្បាប់ជននេះឲ្យមកប្រចាំការរង់ចាំទទួលបណ្តឹងជំទាស់ ឬ អាចជាបណ្តឹងតវ៉ាធ្វើការស្រាវជ្រាវ និង ដោះស្រាយបញ្ហាតាមគោលការណ៍កំណត់"[38]។

### ២.៣.៥. បណ្តឹងជំទាស់ និង ការសម្រុះសម្រួល

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅប្រទេសកម្ពុជាទាំងមូល គឺត្រូវប្រើរយៈពេលយូរដោយសារតែមានដំណាក់កាលជាច្រើន និង ពេលខ្លះត្រូវជួបប្រទះនឹងបណ្តឹងមួយចំនួន ទន្ទឹមនឹងមានបណ្តឹងក៏មានការសម្រុះសម្រួលផងដែរ ដើម្បីអាចដំណើរការ និង បញ្ចប់ទៅដោយជោគជ័យ។ មិនខុសគ្នានោះទេ ដែលនៅក្នុងដំណាក់កាលទី៣នេះ ការបិទផ្សាយជាសាធារណៈនៅភូមិ

---

[36] ដូច៣៥។

[37] បទសម្ភាសជាមួយនឹងមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តព្រៃវែង (ទទួលបន្ទុកបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដីភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន(៣ កក្កដា ២០១៤)។

[38] ដូច១៧។

ពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង ការប្រព្រឹត្តទៅនៃកាបិទផ្សាយ ជៀសមិនផុតពីមានទំនាស់ ហើយទំនាស់កើតទៅជាបណ្ដឹង ផុតពីបណ្ដឹងក៏ត្រូវតែមានដំណោះស្រាយ។

តទៅនេះតារាងខាងក្រោមនេះ នឹងបង្ហាញឲ្យឃើញនូវបណ្ដឹងជំទាស់ដែលកើតមាននៅភូមិពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង បណ្ដឹងដែលកើតឡើងគឺមាន បីករណី ហើយសុទ្ធសឹងតែជាប្រភេទដីកសិកម្ម ជាពិសេសគឺអត្ថន័យនៃបណ្ដឹងដើម្បីឲ្យដឹងថាបណ្ដឹងជាបណ្ដឹងអ្វី មានមូលហេតុយ៉ាងដូចម្ដេច និង ត្រូវធ្វើយ៉ាងណាដើម្បីស្វែងរកដំណោះស្រាយឲ្យបាន៖

តារាង៩៖ បណ្ដឹងជំទាស់ និងការសម្រុះសម្រួល[39]

| បណ្ដឹង | មូលហេតុបណ្ដឹង | ដំណោះស្រាយ |
|---|---|---|
| ១.ប្ដឹងទាមទារក្បាលដីលេខ ៤៦៣ | ដោយសារតែនៅថ្ងៃកើតហេតុ ភាគីម្ខាងស្រវឹងស្រាមកឆារឆៅអ្នកវាស់ដី ធ្វើឲ្យអ្នកវាស់ដីច្រឡំថាជាដីទំនាស់របស់ភាគីម្ខាងទៀត។ | ដោយមានការសម្រុះសម្រួលពីគណៈកម្មការរដ្ឋបាល និង តាមចម្លើយរបស់សាក្សី និង ចាស់ព្រឹទ្ធាចារ្យបានដឹងថាក្បាលដីដែលថាមានទំនាស់នោះគ្រាន់តែជាការយល់ច្រឡំរបស់មន្ត្រីវាស់វែងតែប៉ុណ្ណោះ |
| ២.ប្ដឹងទាមទារក្បាលដីលេខ ៦៦៥ យកធ្វើជាប្លង់កម្មសិទ្ធិ | ដោយសារតែកូនរបស់ភាគីដើមបណ្ដឹងចុះទៅចង្អុលបង្ហាញព្រំដីដល់អ្នកវាស់វែង ចំណែកដើមបណ្ដឹងមិនដឹងទេ បន្ទាប់មកទើបកូនដើមបណ្ដឹងបានទៅបំពេញទិន្នន័យរួច ទើបម្ដាយជាដើមបណ្ដឹងបានដឹង ហើយក៏ពុំព្រមឲ្យដីនោះទៅកូនទេព្រោះគាត់ចាស់ហើយ ពុំមានអ្វីទុកចិញ្ចឹមខ្លួនទេ។ | ភាគីជាម្ដាយសុំទាមទារប្រាក់ចំនួន ១.៨០០.០០០រៀល ពីកូនដែលជាចុងបណ្ដឹង ហើយកូនក៏យល់ព្រម និង សុំធ្វើប័ណ្ណកម្មសិទ្ធិទៅតាមរយៈការសម្រុះសម្រួលរបស់គណៈកម្មការរដ្ឋបាល។ |
| ៣.ប្ដឹងទាមទារក្បាលដីលេខ ៤៨៧ ៥០៤ ៥០៥ ៥០៦ | ទំនាស់រវាងបងប្អូន៧នាក់ ឈ្លោះដណ្ដើមដីកេរ្ដិ៍ឪពុកម្ដាយដែលបានស្លាប់បាត់ទៅហើយ។ | យល់ព្រមបែងចែកដីឲ្យគ្នាទៅវិញទៅមកតាមរយៈការសម្រុះ សម្រួលរបស់គណៈកម្មការរដ្ឋបាល |

[39] ស្ថិតនៅក្នុងទម្រង់បែបបទនៃពាក្យបណ្ដឹងរបស់ហាង យ៉ា យូន ថូនិងតន់ ញ៉ (២៥ ឧសភា ២០១៣)។

តារាងខាងលើនេះបញ្ជាក់អំពី បណ្តឹងជំទាស់ បង្ហាញថាទំនាស់នៃបណ្តឹងទាំងអស់នោះ គឺកើតចេញពីការយល់ច្រឡំរបស់មន្ត្រីវាស់វែងកើតចេញពីទំនាស់កូនបង្កើតដណ្តើមដីពីម្តាយបង្កើត និង កើតចេញពីការដណ្តើមដីរវាងបងប្អូន៧នាក់លើដីកេរ្តិ៍ម្តាយ ឪពុកដែលបានស្លាប់បាត់ទៅហើយ។ ក៏ប៉ុន្តែទោះបីជាមានទំនាស់កើតឡើងក៏ដោយ ក៏រាល់ទំនាស់ទាំងអស់នោះត្រូវបានដោះស្រាយដោយការសម្រុះសម្រួល ស្វែងរកសាក្សី យកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យការព្រមព្រៀងដោយសន្តិវិធីកើតមានឡើងបានដោយមន្ត្រីសុរិយោដី។

## ២.៤. ការសម្រេចលើឯកសារ

នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៣នៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យនៅក្នុងភូមិពោន ក្នុងឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែងគឺត្រូវបានបិទក្នុងរយៈពេល៣០ថ្ងៃ។

តទៅនេះនឹងមានការគូរជាតារាងដែលបញ្ជាក់អំពី ទិន្នន័យក្បាលដីសរុបនៃប្រភេទដី មានប្រភេទដីសាងសង់ ដីកសិកម្ម ចំនួនក្បាលដីដែលប្រែប្រួល បំបែកក្បាលដី បង្រួមក្បាលដី បំពេញទិន្នន័យដីថ្មី ទិន្នន័យអវត្តមានរបស់ម្ចាស់ដី ស្នាមមេដៃរបស់អ្នកជាប់ព្រំ ការតវ៉ា ទំនាស់ផ្សេងៗជាពិសេសទំនាស់ដែលអាចសម្រុះសម្រួលបាន ចំនួនក្បាលដីត្រឹមត្រូវគ្មានទំនាស់ ចំនួនក្បាលដីសរុបក្រោយពេលបិទផ្សាយមានដូចជា ដីសាងសង់ ដីកសិកម្ម ចំនួនក្បាលដីមិនត្រូវចេញប័ណ្ណដោយសារម្ចាស់ដីអវត្តមាន និង ចំនួនក្បាលដីមានប័ណ្ណចាស់ យកមកបញ្ជាក់ដូចខាងក្រោម៖

តារាង១០៖ លទ្ធផលសម្រេចលើឯកសារក្រោយពេលបិទផ្សាយ[40]

| ល.រ | សម្រង់ទិន្នន័យក្បាលដី | ចំនួនក្បាលដី |
|---|---|---|
| ១ | ចំនួនក្បាលដីសរុបមុនពេលប្រកាសៈ | ១០៣៦ |
| | – ដីសាងសង់ | ១៩៤ |
| | – ដីកសិកម្ម | ៨៩២ |
| ២ | ចំនួនក្បាលដីដែលប្រែប្រួល | |
| | ២.១. ឯកសារវិនិច្ឆ័យដែលសុំធ្វើការកែតម្រូវ | ១៧ |
| | – ប្តូរប្រភេទដី | ០៨ |

40 ដូច៣៣ ។

| | | |
|---|---|---|
| | – ពីដីកសិកម្មទៅដីសាងសង់ | ០៨ |
| | – ប្តូរឈ្មោះម្ចាស់ដី | ០៤ |
| | – កែតម្រូវលើប្លង់ | ០២ |
| | – ប្តូរទីតាំងដី | ០២ |
| | – ប្តូរប្រភេទទ្រព្យពីទ្រព្យលីវ ទៅជាទ្រព្យរួមប្តីប្រពន្ធ | ០១ |
| | ២.២.បំបែកក្បាលដី | ០៣ |
| | – ដីកសិកម្ម | ០២ |
| | – ដីសាងសង់ | ០១ |
| | ២.៣.បង្រួមក្បាលដី | ០០ |
| | ២.៤. បំពេញទិន្នន័យថ្មី | ១២ |
| | – ក្រោយពីសម្រុះសម្រួលបាន | ០៥ |
| | – ក្រោយពីប្តូរឈ្មោះម្ចាស់ដី | ០៤ |
| | – ក្រោយពីបំបែកក្បាលដី | ០៣ |
| | ២.៥. ម្ចាស់អវត្តមាន | ៥៦ |
| | – មិនបានមកបំពេញទិន្នន័យ | ៥០ |
| | – ដីកសិកម្ម | ៥០ |
| | – មិនបានចូលរួមពិនិត្យពេលបិទផ្សាយ | ០៦ |
| | ២.៦. ខ្វះស្នាមមេដៃអ្នកជាប់ព្រំ | ១២ |
| ៣ | ការតវ៉ា និង ទំនាស់ផ្សេងៗមាន៣ករណី<br>សម្រុះសម្រួលបាន: ៣ករណី | ០៦<br>០៦ |
| ៤ | ចំនួនក្បាលដីត្រឹមត្រូវគ្មានទំនាស់ (គិតបញ្ចូលទាំងម្ចាស់អវត្តមាន) | ១០៣៣ |
| ៥ | ចំនួនក្បាលដីសរុបក្រោយពេលបិទផ្សាយ:<br>– ដីសាងសង់ និង ដីកសិកម្ម | ១០៣៩<br>១៥៣និង៨៨៦ |
| ៦ | ចំនួនក្បាលដីមិនត្រូវចេញបណ្ណ:<br>– ម្ចាស់អវត្តមាន<br>– ដីកសិកម្ម និង ចំនួនក្បាលដីមានប័ណ្ណចាស់ | ៥០<br>៥០<br>៥០ និង ០០ |

តារាងខាងលើនេះ បង្ហាញពីការឆ្លងកាត់ការងារជាច្រើន ក៏ដូចជាមានបញ្ហាមួយចំនួនបានកើតឡើង ក៏ការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធក្នុងឃុំស្មោងជើងនៅតែអាចទទួលលទ្ធផលជាវិជ្ជមានដដែល ដោយសារតែការងារបច្ចេកទេសដែលរួមមាន ការកំណត់ព្រំការវាស់វែង និង ការស្រង់ទិន្នន័យក្បាលដីអាចប្រព្រឹត្តទៅ បានលឿនអាស្រ័យមានការខិតខំយកចិត្តទុកដាក់ អនុវត្តយ៉ាងល្អរបស់លោកនាយក PPMO ព្រមទាំងមន្ត្រីកម្មវិធីទាំងអស់ និង ដោយមានការជួយឧបត្ថម្ភពីសំណាក់ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ពិសេសពីកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) ទាំងបច្ចេកទេសសំភារៈ និងថវិកា ការជួយជ្រោមជ្រែងពីឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ដោយមានការចូលរួមរបស់អ្នកកាន់កាប់ដី និង អ្នកជាប់ព្រំគ្រប់រូបមកចង្អុលបង្ហាញក្បាលដី និង មកចូលរួមបានទៀងទាត់តាមពេលនៅទីកន្លែងកំណត់រួម ទាំងនាំយកមកជាមួយនូវសំណុំឯកសារដែលពាក់ព័ន្ធ។

## ២.៥. ការចេញប័ណ្ណ

ការចេញប័ណ្ណជាដំណាក់កាលចុងក្រោយក្នុងចំណោមដំណាក់កាលទាំងប្រាំ នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ហើយក៏ជាដំណាក់កាលមួយនៃការចេញជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋផងដែរ។

លក្ខណៈសំខាន់ដែលត្រូវតែលើកយកមកបង្ហាញ នៅក្នុងដំណាក់កាលនេះគឺគោលការណ៍នៃការចេញប័ណ្ណ និង ពិភាក្សាអំពីនីតិវិធីនៃការចែកប័ណ្ណក្នុងឃុំ ស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែងដូចខាងក្រោមនេះ៖[41]

### ២.៥.១. គោលការណ៍នៃការចេញប័ណ្ណ

ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនចំពោះក្បាលដីដែលកាន់កាប់ដោយសន្តិវិធី និង មិនមានទំនាស់ចាប់ពី៥ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់ភូមិបាលឆ្នាំ២០០១។

ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដី ចំពោះក្បាលដីដែលកាន់កាប់ដោយសន្តិវិធី និងមិនមានជំទាស់ ហើយមានរយៈពេលតិចជាងប្រាំឆ្នាំមុនពេលច្បាប់ភូមិបាល២០០១ ចូលជាធរ

[41] ដូច១៧, ទំព័រ៩ ដល់១០។

មាន។ ប័ណ្ណប្រភេទនេះអាចប្តូរយកវិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុនៅពេលដែលរយៈពេលនៃការកាន់កាប់ដី ឬ អចលនវត្ថុនោះបានគ្រប់៥ឆ្នាំ ឬលើស។

អាចចេញប័ណ្ណជូនប័ណ្ណបានចំពោះតែក្បាលដី ឬចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ។

ការប្រគល់ប័ណ្ណត្រូវមានសៀវភៅសម្រាប់កត់ត្រាឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់ និងកត់ឈ្មោះរួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាង។ មន្ត្រីសុរិយោដី គឺមិនត្រូវបានអនុញ្ញាតឲ្យប្រគល់ ប័ណ្ណជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែងតែម្ចាស់សិទ្ធិទទួលមរណៈភាព ត្រូវបាត់ខ្លួន បាត់បង់សមត្ថភាពដែលច្បាប់ទទួលស្គាល់ ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស។

នៅពេលទទួលប័ណ្ណថ្មី ម្ចាស់អចលនវត្ថុត្រូវប្រគល់ប័ណ្ណចាស់ (ប័ណ្ណស្លាបមាន់) ឬ ប័ណ្ណសម្គាល់សិទ្ធិផ្សេងៗ និង បង្កាន់ដៃកាន់កាប់ដីដែលទាក់ទងនឹងសិទ្ធិលើដី ឬអចលវត្ថុនោះជូនមន្ត្រីសុរិយោដីប្រសិនបើមាន។

ករណីពិសេស និង ចាំបាច់ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបានតែត្រូវបញ្ជាក់ច្បាស់ពីមូលហេតុ ដែលមិនអាចមកទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឲ្យប្រគល់ប័ណ្ណ នៅគេហដ្ឋានរបស់កម្មសិទ្ធិករ ឬ ភោគីដោយមន្ត្រីសុរិយោដីយ៉ាងតិច ២នាក់។

នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬ អចលនវត្ថុ ត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬ អចលនវត្ថុនោះជូនមន្ត្រីសុរិយោដីប្រសិនបើមាន។

ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព (នីតិបុគ្គលសាធារណៈមានជាអាទ៏ សាលារៀន សាលាឃុំ...នីតិបុគ្គលឯកជន មានជាអាទ៏សមាគម ក្រុមហ៊ុន) មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។

ចំពោះដី ឬ អចលនវត្ថុរបស់សមូហភាព ដូចជា វត្ត ឬ សហាគមន៍ជនជាតិដើមភាគតិចនៅក្នុងប័ណ្ណ ក៏ត្រូវចុះឈ្មោះ វត្ត ឬ សហាគមន៍...ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។ ទាក់ទងដល់ការប្រើសិទ្ធិ និង ការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានា ក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងខ្លួនតាមវិធីផ្សេងៗ គ្នាដូចជានីតិបុគ្គលសាធារណៈ មានលិខិតតែងតាំងនីតិបុគ្គលឯកជនមានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬ ប្រធាន សមាគម វត្ត មានប្រធាន គណៈកម្មការវត្ត សហាគមន៍

ជនជាតិដើមភាគតិចមានប្រធានសហគមន៍...។ តំណាងស្របច្បាប់ទាំងអស់នេះមានសិទ្ធិ និង កាតព្វកិច្ចទាក់ទងនឹងអចលនវត្ថុដូចម្ចាស់សិទ្ធិជារូបវន្តបុគ្គលដែរ។

ប័ណ្ណដី ឬ អចលនវត្ថុ របស់នីតិបុគ្គលសាធារណៈ និង ឯកជនត្រូវប្រគល់ឲ្យតំណាងស្រប ច្បាប់នៃនីតិបុគ្គលនីមួយៗជាអ្នកទទួលយករក្សាទុក។ មួយវិញទៀតចំពោះប័ណ្ណដី ឬ អចលនវត្ថុ របស់សម្ធបាភាព ត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬ ប្រធានសហគមន៍ទទួលយក និង រក្សា ទុក។

រីឯប័ណ្ណដី ឬ អចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និង ឯកជនត្រូវប្រគល់ឲ្យតំណាងស្រប ច្បាប់នៃនីតិបុគ្គលនីមួយៗជាអ្នកទទួលយក និង រក្សាទុក។ ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់ សម្ធបាភាពត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬប្រធានសហគមន៍ទទួលយក និង រក្សាទុក (សារា ចរណែនាំលេខ០០១ ដនស សជ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការអនុវត្តនីតិវិធីនៃការ កសាងបងលង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី)។

## ២.៥.២. នីតិវិធីក្នុងការចែកប័ណ្ណ

បន្ទាប់ពីការពិភាក្សាយ៉ាងលម្អិតទៅលើដំណាក់កាលទាំង៤ កន្លងមកនៅក្នុងដំណាក់កាល ទី៥ នៃនីតិវិធីក្នុងការចែកប័ណ្ណនេះ ជាលទ្ធផលគឺខាង "គណៈកម្មការរដ្ឋបាលសុរិយោដីខេត្តព្រៃ វែងបានស្នើសុំទៅកាន់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ជាកិច្ចបន្ទាប់មកទៀតអភិបាលនៃ គណៈអភិបាលខេត្តព្រៃវែង ក៏បានចេញជាសេចក្តីជូនដំណឹងស្តីអំពីការចែកវិញ្ញាបនបត្រសម្គាល់ ម្ចាស់អចលនវត្ថុ និង មោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិ កាន់កាប់អចលនវត្ថុ"[42] ។

ការបិទសេចក្តីជូនដំណឹងនៅនឹងមួយកន្លែង មិនអាចផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋទាំងអស់ អាចទទួលដឹងលឺបានគ្រប់គ្នានោះទេ ដោយសារតែប្រជាពលរដ្ឋភាគច្រើនមានភាពមមាញឹកក្នុង ការប្រកបរបរចិញ្ចឹមជីវិត ដូចនេះដើម្បីលុបបំបាត់នូវបញ្ហានេះ "គណៈកម្មការរដ្ឋបាលសុរិយោដី ខេត្តព្រៃវែង ក៏បានធ្វើការស្នើសុំតាមរយៈឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ និង ជានាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីទៅកាន់ CPMO ឲ្យជួយទំនាក់ទំនង ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍អំពីសេចក្តីជូនដំណឹងស្តីពី ការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់

[42] សេចក្តីជូនដំណឹងស្តីពី ការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និង មោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, លេខ៨៥០/១៣ សជណ, ១៤ មិថុនា ២០១៣។

អចលនវត្ថុ និង មោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ"[43]។

ជាមួយគ្នានេះ ដើម្បីបង្កើនភាពឆាប់រហ័សនៃពេលវេលា ធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋអាចទទួលបាននូវវិញ្ញាបនបត្រថ្មីរបស់ខ្លួនទាន់ពេលនោះ គឺគណៈកម្មការរដ្ឋបាលនៃមន្ទីរសុរិយោដីខេត្តព្រៃវែងក្នុងតំបន់ស្មោងជើង ក៏បានដាក់សំណើមួយទៀតទៅកាន់ ឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជាតាមរយៈការព្រមព្រៀងរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង សុំជួយផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីអំពីការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និង មោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ តាមទូរទស្សន៍ជាតិកម្ពុជាថែមទៀត។[44]

ផលវិបាកដែលកើតមានឡើងនៅក្នុងដំណាក់កាលនេះ គឺមិនមាននោះទេក៏ព្រោះតែមន្រ្តីសុរិយោដីលើករណីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងឃុំស្មោងជើង ស្រុកកំចាយមារ នៅក្នុងខេត្តព្រៃវែងនេះ មានការប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ អត់ធ្មត់រាល់បញ្ហា និង ព្យាយាមស្វែងរកដំណោះស្រាយដែលកើតមានឡើងកន្លងមក នៅក្នុងដំណាក់កាលទាំង៥ខាងលើរួចទៅហើយ ជាពិសេសព្រមទាំងមានការសហការយ៉ាងល្អប្រសើររបស់ប្រជាពលរដ្ឋផងនោះ ធ្វើអោយការអនុវត្តនៅដំណាក់កាលបញ្ចប់នេះក៏បញ្ចប់ទៅដោយជោគជ័យ។

[43] សេចក្តីស្នើសុំឲ្យCPMO តាមរយៈឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្រ្ត និង ជានាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី, លេខ ០១៦/១៣ PPMO/PV, ១៤ មិថុនា ២០១៣។

[44] សំណើសុំជួយផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និង មោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ តាមទូរទស្សន៍ជាតិកម្ពុជា, លេខ ១៨៣/១៣លស, ១៤ មិថុនា ២០១៣។

# ជំពូកទី៣

# បញ្ហាប្រឈម ដំណោះស្រាយ និង ផលប្រយោជន៍នៃការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធក្នុងខេត្តព្រៃវែង

## ៣.១. បញ្ហាប្រឈម

ជំពូកនេះពិភាក្សាពីបញ្ហាប្រឈមដែលបានកើតមានឡើងនៅក្នុង ឃុំ ស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង ដែលជាតំបន់មួយក្នុងចំណោមតំបន់ជាច្រើននៃតំបន់ត្រូវធ្វើការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ បញ្ហាប្រឈមដែលកើតឡើងលេចធ្លោជាងគេរួមមាន ដីទំនាស់ ស្ថានភាពភូមិសាស្ត្រ សំភារៈ ពេលវេលា សង្គ្រាម ចំណេះដឹងផ្នែកច្បាប់ ការអនុវត្តរបស់មន្ត្រីអនុវត្ត ឯកសារ ថវិកា ដូចខាងក្រោម៖

### ៣.១.១. ដីទំនាស់

របាយការណ៍បូកសរុប ទៅលើការអនុវត្តន៍នីតិវិធី នៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធលេខ៦៧០ ថ្ងៃទី១៤ មិថុនា ២០១៣ បានបង្ហាញឲ្យឃើញថា មានដីទំនាស់បីករណី គឺជាប្រភេទដីកសិកម្ម និង ដីលំនៅឋាន ជាការប្តឹងតវ៉ាទាមទារក្បាលដីមកធ្វើជាកម្មសិទ្ធិស្របច្បាប់។ លើសពីនេះទៅទៀតបើយោងតាមរបាយការណ៍ដដែលនេះក៏បានបង្ហាញផងដែរថា មានដីទំនាស់មុនពេលបិទផ្សាយ ជាប្រភេទដីសាងសង់ចំនួន១ និង ប្រភេទដីកសិកម្មចំនួន៥ក្បាលដី។[45]

ម្ចាស់ដីខ្លះខ្វះខាតលើការដាំបង្គោលព្រំដីមិនបានរឹងមាំ ចំណែកការលក់ដូរ ឬ ដាក់បញ្ចាំពុំមានកិច្ចសន្យាច្បាស់លាស់។

ម្ចាស់ដីមួយចំនួនទៀត ពួកគាត់ដណ្តើមដីគ្នាទៅវិញទៅមក មិនចង់ដាក់ថាជាដីរួមគ្នាទេ ព្រោះមានទំនាស់ផ្ទៃក្នុងនៅក្នុងគ្រួសារ។[46]

មូលហេតុផលវិបាកទាំងអស់នេះជាហេតុ ធ្វើឲ្យមានទំនាស់ពេលវាស់វែងផ្តល់កម្មសិទ្ធិលើដីធ្លី។

[45] ដូច៣៣។

[46] ដូច១៨។

### ៣.១.២. ស្ថានភាពភូមិសាស្ត្រ

ស្ថានភាពដីនៅភូមិពោន ឃុំស្មោងជើងនោះគឺវាសំបូរទៅដោយព្រៃ បង្កឲ្យមានភាពលំបាកក្នុងការកំណត់ព្រំប្រទល់ដី ជាពិសេសទៀតគឺ នៅពេលមានភ្លៀងកាន់តែលំបាកលើសដើម ក្នុងការកំណត់ព្រំដី។[47]

### ៣.១.៣. សំភារៈ

សំភារៈសម្រាប់កំណត់ព្រំដីមួយចំនួនដូចជា ខ្សែម៉ែត្រ ព្រីសកែង បង្គោលតំរង់ មានសភាពចាស់អស់ហើយ ហើយឆាប់ខូចនៅពេលយកមកប្រើប្រាស់ពីព្រោះតែសំភារៈទាំងអស់នេះត្រូវបានប្រើពីតំបន់មួយ ទៅតំបន់មួយទៀតជាច្រើនដង និង គ្មានការផ្លាស់ប្តូរ។[48]

### ៣.១.៤. ពេលវេលា

វាពិតជាមានភាពយឺតយាវខ្លះដែរចំពោះការបញ្ជូន ឯកសារមួយចំនួនដូចជា ការផ្ទេរលិខិតទាំងលិខិតអញ្ជើញ លិខិតស្នើសុំ សេចក្តីសម្រេច សេចក្តីជូនដំណឹងផងដែរគឺ ត្រូវប្រើពេលវេលារង់ចាំច្រើនថ្ងៃទើបទទួលបានហត្ថលេខា ដើម្បីយកទៅអនុវត្តបន្ត។ លើសពីនេះទៅទៀតសូម្បីតាមរបាយការណ៍ចុះត្រួតពិនិត្យគុណភាពក្បាលដី ក៏មានការយឺតយាវដែរព្រោះតែឯកសារដែលត្រូវបំពេញខ្វះស្នាមមេដៃប្តី ពេលខ្លះទៅក៏ខ្វះស្នាមមេដៃប្រពន្ធ ជាពិសេសមានការប្តូរឈ្មោះមិនច្បាស់លាស់ ដែលជាមូលហេតុពិបាក យឺតពេលក្នុងការស្រង់យកពិតមានដាក់ក្នុងឯកសារប្រមូលទិន្នន័យក្បាលដី។ មួយវិញទៀតចំពោះម្ចាស់ដីខ្លះក៏ពុំបានមកចូលរួមឲ្យបានទាន់ពេលវេលាលើការកំណត់ព្រំដី និង ការវិនិច្ឆ័យធ្វើឲ្យយឺតយាវលើការប្រមូលទិន្នន័យក្បាលដី។[49]

ម្ចាស់ដីខ្លះមិនទាន់មានអត្តសញ្ញាណប័ណ្ណគ្រប់គ្រាន់ ខ្វះសារតាឪពុកម្តាយម្ចាស់កម្មសិទ្ធិជាមួយគ្នានេះដែរគ្រួសារមួយចំនួនលែងលះ ឬ ចុះចោលដោយពុំមានការបញ្ជាក់ច្បាស់លាស់នាំឲ្យលំបាកក្នុងការកំណត់សិទ្ធិក៏ជាហេតុបង្កជាទំនាស់លើដីធ្លីពេលធ្វើការចុះបញ្ជី។[50]

ម្ចាស់ដីកាន់កាប់ដីខ្លះទៀត បានធ្វើការផ្លាស់ប្តូរពេលវេលាមិនទៀងទាត់ក្នុងការកាន់កាប់ ។

---

[47] ដូច២៦។

[48] បទសម្ភាសជាមួយនឹងមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សុរិយោដីខេត្តព្រៃវែង (ទទួលបន្ទុកវាស់វែងដីធ្លីនៅឃុំស្មោងជើង ខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន (៣ កក្កដា ២០១៤) ។

[49] ដូច២៦ ។

[50] ដូច៤៨។

ជាក់ស្តែងបើយោងទៅតាមការសម្ភាសជាមួយ មន្ត្រីវាស់វែងដីផ្ទាល់តែម្តង គឺពួកគាត់បានប្រាប់ថា វាពិតជាមានការពិបាកខ្លះហើយគឺនៅពេលដែលពួកគាត់ធ្វើការវាស់វែងដី មានម្ចាស់ដីខ្លះអវត្តមានមិនអាចមកបាន ជាងនេះទៅទៀតពេលដែលពួកគាត់កំពុងតែវាស់ ស្រាប់តែមានម្ចាស់ដីម្នាក់គាត់មិនសុខចិត្តហើយបានលើកឡើងថាព្រំដីគាត់មិនមែនត្រង់ហ្នឹងទេ ស្របពេលជាមួយដែលម្ចាស់ព្រំដីម្ខាងទៀតប្រកែកថាអត់មែនអញ្ចឹងទេព្រំដីកន្លែងហ្នឹងមិនមែនតែប៉ុណ្ណឹងទេ គឺនៅលើព្រំដីរបស់ម្ចាស់ព្រំដីម្ខាងទៀត។

### ៣.១.៥. សង្គ្រាម

នៅក្នុងឃុំស្មោងជើង បន្ទាប់ពីសង្គ្រាមក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដីរបស់ប្រជាជនមានការប្រែប្រួលច្រើនដែលមិនអាចកំណត់ឲ្យបានច្បាស់លាស់ទេថាដីនោះ ជាដីរបស់នរណាឡើយ។[51]

### ៣.១.៦. ចំណេះដឹងផ្នែកច្បាប់ និង ច្បាប់

នៅមានកម្រិតនៅឡើយចំពោះការចាប់យក នូវការអនុវត្តផ្សេងដើម្បីទទួលបានកម្មសិទ្ធិ ឬ វិញ្ញាបនបត្រលើដីរបស់ប្រជាពលរដ្ឋ ព្រោះកន្លងមកមិនមានការចុះទៅពន្យល់ណែនាំដល់លំនៅឋាន អំពីច្បាប់ បទបញ្ញត្ត និងគោលការណ៍នានាដែលពាក់ព័ន្ធនិងការកាន់កាប់ ប្រើប្រាស់ និង គ្រប់គ្រងដីធ្លីឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយជាហេតុបង្កឲ្យមានទំនាស់។[52]

រីឯច្បាប់វិញគឺនៅពុំទាន់មានច្បាប់កំណត់ពី ចំណី អូរ ប្រឡាយ ផ្លូវលំ ជាហេតុនាំឲ្យមន្ត្រីជំនាញមានការស្ទាក់ស្ទើរក្នុងការរក្សាទុក ឬ ប្រគល់សិទ្ធិឲ្យជាឯកជនដល់ប្រជាពលរដ្ឋ។[53]

លើសពីនេះទៅទៀត ប្រជាពលរដ្ឋតំណាងម្នាក់បានប្រាប់ពីផលវិបាករបស់គាត់ថា ប្រជាពលរដ្ឋមួយចំនួនពួកគាត់មិនសូវយល់ដឹងពីបញ្ហាផ្លូវច្បាស់នោះទេ ព្រោះថាពេលមានគណៈកម្មការបើកវគ្គបណ្តុះបណ្តាល ពួកគាត់នោះមិនបានមកទេ ដោយរវល់ទៅលើការងារស្រែចំការ ហើយអ្នកខ្លះទៅក៏មានជម្ងឺមិនអាចមកទទួលចំណេះដឹងស្តីពីដីធ្លីនេះបាន។ អ្វីដែលពិបាកជាងនេះទៅទៀតនោះគឺ ប្រជាពលរដ្ឋខ្លះគាត់មិនចេះអក្សរទេ ជួនទៅពេលមានគ្រួសារប្រហែលជាពីរទៅបី

[51] ដូច២៦។

[52] ដូច១៩។

[53] ដូច២៦។

គ្រួសារ គឺមិនចេះអក្សរមួយគ្រួសារតែម្តងជាហេតុនាំឲ្យមានការលំបាក មិនដឹងថាគួរយកឯកសារមក ឬ មិនគួរយកឯកសារណាមកនោះទេ។[54]

### ៣.១.៧. ការអនុវត្តមិនត្រឹមត្រូវរបស់មន្ត្រីអនុវត្ត

មន្ត្រីវាស់វែងមួយចំនួនបានវាស់វែង និង កំណត់ច្រឡំលើក្បាលដីរបស់ប្រជាពលរដ្ឋធ្វើឲ្យមានទំនាស់រវាងម្ចាស់ដី និង អ្នកជាប់ព្រំដី។

មន្ត្រីពិនិត្យ និង កែតម្រូវលើពាក្យខ្លះដែលមានកំហុសពេលធ្វើការបិទផ្សាយ និង មន្ត្រីវាស់វែងខ្លះ ទាមទាររកប្រាក់ចំណេញចូលហោប៉ៅរបស់ខ្លួនដោយខុសច្បាប់ ហើយប្រាប់បុគ្គលដែលមករកខ្លួននោះថា បើឲ្យខ្លះទៅវានឹងកែឆាប់ហើយ ឬ ក៏នឹងបានវាស់វែងឲ្យបានត្រឹមត្រូវជាងមុន។

មន្ត្រីកំណត់ព្រំដីខ្លះ កំណត់រកតែភាពលំអៀងដើម្បីបានប្រាក់ខ្លះ។

### ៣.១.៨. ឯកសារ

ផលវិបាករបស់មន្ត្រីវិនិច្ឆ័យគឺ ស្ថិតនៅលើប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋមួយចំនួនខ្វះឯកសារណបច្រើន ដូចជាប្រជាពលរដ្ឋខ្លះបានមកដល់ទីតាំង ដើម្បីផ្តល់ពិតមានទៅកាន់មន្ត្រីវិនិច្ឆ័យក្នុងការប្រមូលទិន្នន័យ ប៉ុន្តែពេលដែលមកដល់ភ្លាមប្រជាពលរដ្ឋនោះបែរជាប្រាប់ថា គាត់មិនបានយកឯកសារមកតាមទេ ដូចជាអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើតជាដើម។

លើសពីនេះទៅទៀតប្រជាពលរដ្ឋខ្លះមានទីលំនៅឆ្ងាយ ហើយអ្នកខ្លះទៀតមកបំពេញឯកសារមិនគ្រប់គ្នាទេជួនមានស្នាមមេដៃប្រពន្ធខ្វះប្តី ជួនទៅមានស្នាមមេដៃប្តីខ្វះប្រពន្ធ។

មួយវិញទៀតអ្វីដែលពិបាកជាងនេះទៅទៀតនោះ គឺប្រជាពលរដ្ឋខ្លះម្ចាស់ដីតែម្នាក់ទេ ក៏ប៉ុន្តែមានដីច្រើនកន្លែងខ្វះខាតការបំពេញឯកសារមិនឈប់ឈរទេ ពេលខ្លះទៅថែមទាំងមកដល់មិនទាន់បំពេញកង្វះខាតលើឯកសារមិនទាន់គ្រប់ជ្រុងជ្រោយផងក៏ទៅផ្ទះវិញបាត់។

បន្ថែមពីនេះទៀតប្រជាពលរដ្ឋខ្លះទៅ ឯកសារដើមរបស់ពួកគាត់រលុបអក្សរមិលមិនយល់ហើយកែពាក្យមើលទៅមានលក្ខណៈស្មុគស្មាញមិនដឹងថាត្រូវប្រើវិធីណាមួយទើបមើលយល់នោះទេ។

មូលហេតុទាំងអស់នេះហើយដែលជាហេតុ ធ្វើឲ្យមន្ត្រីវិនិច្ឆ័យពិបាកក្នុងការប្រមូលទិន្នន័យឲ្យបានច្បាស់លាស់ចូលទៅក្នុងបែបបទប្រមូលទិន្នន័យក្បាលដី។

[54] បទសម្ភាសន៍ប្រជាពលរដ្ឋ ស្រុកកំចាយមារ ខេត្តព្រៃវែង, ២៦ មិថុនា ២០១៤។

### ៣.១.៩. ថវិកា

ចំពោះបញ្ហាថវិកានេះ គឺទៅលើការប្រើបរាស់យន្តហោះដើម្បីថតយកប្លង់ដីពីលើអាកាសមកខាងក្រោមវិញ បើទោះបីជាក្រសួងជាអ្នកចេញថវិកាក៏ដោយ ក៏វានៅតែជាផលវិបាកដដែល ព្រោះថវិកា ដែលត្រូវយកមកប្រើប្រើប្រាស់ទាំងអស់នោះគឺ មានចំនួនរហូតដល់ទៅ២ ម៉ឺនដុល្លារសហរដ្ឋអាមេរិចឯណោះ ដែលជាហេតុធ្វើឲ្យបាត់បង់ថវិកាដែលត្រូវបើកប្រាក់ខែជូនដល់មន្ត្រីគ្រប់គ្រងប្រព័ន្ធដីទៅវិញនាពេលឆ្នាំ២០១៤នេះ។[55]

## ៣.២.ដំណោះស្រាយ

បើទោះបីជាមានបញ្ហាកើតឡើងជាបន្តបន្ទាប់ច្រើនយ៉ាងណាក៏ដោយ ក៏ដំណោះស្រាយនៅតែមានជានិច្ច ព្រោះថាបើមិនមានដំណោះស្រាយទេនោះ ក៏មិនអាចធ្វើការចុះបញ្ជីលក្ខណៈជាប្រព័ន្ធ នៅភូមិ ពោន ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែងបានជោគជ័យមកដល់ថ្ងៃនេះដែរ។ ទន្ទឹមនឹងនេះដំណោះស្រាយទាំងអស់នោះគឺបានកើតចេញពី ការព្យាយាម អត់ធ្មត់ យកចិត្តទុកដាក់ សហការគ្នាទៅវិញទៅមក។

ជាពិសេសទាំងគណៈអភិបាលខេត្ត មេភូមិ មេឃុំ ចាស់ព្រឹទ្ធាចារ្យ មន្ត្រីវិនិច្ឆ័យមន្ត្រីវាស់វែង និងមន្ត្រីកំណត់ព្រំដី ព្រមទាំងគណៈកម្មការរដ្ឋបាលទាំងអស់ ជាពិសេសគឺប្រជាពលរដ្ឋផ្ទាល់តែម្តង ពោរពេញទៅដោយភាពស្និតស្នាញ ភាពតស៊ូ ចូលរួមដោះស្រាយបញ្ហាដោយការប្រើចំណេះដឹងដែលខ្លួនទទួលបានពីក្រសួងដែនដីនគររោបនីយកម្ម និង សំណង់មិនថាក្រុង ឬខេត្ត មកធ្វើការសម្រុះសម្រួលឈានទៅដល់ការព្រមព្រៀង ដោយមិនចាំបាច់ទៅដល់ប្រព័ន្ធតុលាការនោះទេ រួមផ្សំនិងប្រជាពលរដ្ឋចេះអត់អោនឲ្យគ្នាទៅវិញទៅមកផងដែរ។[56]

ដំណោះស្រាយដែលវៃឆ្លាតបំផុតរបស់មន្ត្រីវិនិច្ឆ័យ មន្ត្រីវាស់វែង គឺនៅពេលដែលប្រជាពលរដ្ឋជាម្ចាស់ដីមានទំនាស់ គឺពួកគាត់ធ្វើការកត់ត្រាថាជាដីទំនាស់ ហើយបន្ទាប់មកទៀតទើបពួកគាត់ហៅម្ចាស់ដីម្ខាងមកសម្រួលមុនសិន បន្ទាប់មកបើបានសម្រេចភាគីម្ខាងហើយ ទើបបន្តទៅសម្រួលភាគីម្ខាងម្ខាងទៀត ដែលជាលក្ខណៈល្អប្រសើរនៃការស្វែងរកដំណោះស្រាយជូនដល់ភាគីទាំងសងខាង។

[55]ដូច៤៨។

[56]ដូច២៦។

## ៣.៣. ផលប្រយោជន៍

ផលប្រយោជន៍នៅទីនេះ គឺជាផលប្រយោជន៍ដែលប្រជាពលរដ្ឋទទួលបាន ក្រោយពីពួកគេបានចូលរួមសហការយ៉ាងសកម្ម ជាមួយគណៈកម្មការរដ្ឋបាលក្នុងតំបន់ស្មោងជើងដែលជាលទ្ធផល ពួកគាត់ក៏ទទួលបាននូវសិទ្ធិស្របច្បាប់ នឹង ទទួលបានប័ណ្ណកម្មសិទ្ធិ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថែមទៀត ហើយប្រយោជន៍ដែលពួកគាត់ទទួលបាននោះមានដូចជា ធ្វើជាភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិស្របច្បាប់ កសាងអនាគតសម្រាប់ខ្លួនពួកគាត់ផ្ទាល់ និងសម្រាប់អ្នកដែលទទួលវេនពីពួកគាត់ សំខាន់ជាងនេះទៅទៀត គឺ មានសុវត្ថិភាព ស្ថិរភាព ហើយជម្លោះរបស់ពួកគាត់ក៏ត្រូវបានកាត់បន្ថយឬ លុបបំបាត់ ជាពិសេសទៀតគឺ ធ្វើឲ្យទីផ្សារដីរបស់ពួកគាត់ប្រកបដោយទំនុកចិត្ត ដីធ្លីនឹងធ្លាក់ក្នុងដៃអ្នកផលិតពិតប្រាកដ ការវិនិយោគនឹងកើនឡើង ហើយលទ្ធភាពរកឥណទានសម្រាប់ធ្វើអាជីវកម្មនឹងមានភាពងាយស្រួល។

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវចំពោះប្រធានបទស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (ករណីខេត្តព្រៃវែង)បានបង្ហាញឲ្យឃើញថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅខេត្តព្រៃវែង មិនខុសពី ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅទូទាំងប្រទេសកម្ពុជាទេ។ ម្យ៉ាងវិញទៀត លក្ខណៈមិនខុសគ្នានេះ គឺនៅត្រង់ថា មានប្រាំដំណាក់កាលដូចគ្នា ដូចជាដំណាក់កាលត្រៀមរៀបចំ ដំណាក់កាលប្រតិបត្តិការបច្ចេកទេស ដំណាក់កាលបិទផ្សាយជាសាធារណៈ ដំណាក់កាលសម្រេចលើឯកសារ និងចុងក្រោយ គឺដំណាក់កាលចែកប័ណ្ណ។

ជាមួយគ្នានេះដែររាល់ដំណាក់កាលនីមួយៗ បានពើបប្រទះនឹងបញ្ហាមួយចំនួនដូចជា បញ្ហាលើទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រសំបូរព្រៃ និង ទឹកពិបាកវាស់វែង សំភារៈវាស់វែងឆាប់ខូច ពេលវេលាមានសភាពយឺតយាវ ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ប្រជាពលរដ្ឋខ្លះមិនចេះអក្សរជាហេតុច្រឡំឯកសារជាញឹកញាប់។

ជាថ្មីម្តងទៀតបើទោះបីជាប្រទះនឹងបញ្ហាទាំងអស់ ក្នុងកថាខណ្ឌទី២ខាងលើនេះក៏ដោយ ក៏ពុំមានអ្វីដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការនេះទេ ព្រោះប្រជាពលរដ្ឋដែលគាត់មិនចេះអក្សរ គឺពួកគាត់អាចស្តាប់ និងមានការយល់ដឹងនូវដំណើរការទាំងមូលបាន តាមរយៈការផ្សព្វផ្សាយរបស់មន្ត្រីផ្សព្វផ្សាយ និងដោយមានការជួយជ្រោមជ្រែងពីសំណាក់អាជ្ញាធរមូលដ្ឋានក្នុងការជួយប្រមូលប្រជាពលរដ្ឋ និង ការបញ្ជាក់នូវរាល់លិខិតស្នាម ផ្សេងៗដែលទាក់ទងទៅនឹងអត្តសញ្ញាណក្បាលដី និង អត្តសញ្ញាណម្ចាស់ដី។

លើសពីនេះទៅទៀត ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មន្ត្រីវិនិច្ឆ័យមានការយល់ដឹងច្រើនពីនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលជាផ្នែកមួយល្អនៅក្នុងការប្រមូលពិតមាននូវអត្តសញ្ញាណក្បាលដី អត្តសញ្ញាណម្ចាស់ដី និងសិទ្ធិដែលមានរបស់ម្ចាស់ដីលើអចលនវត្ថុ ដើម្បីកសាងនូវប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដីមួយប្រកបទៅដោយភាពសុក្រឹត្យត្រឹមត្រូវ ឈានទៅរកការចេញវិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុជូនដល់ម្ចាស់ដី និងអ្នកកាន់កាប់ដីប្រកបដោយការការជឿទុកចិត្តព្រមទាំងធានាបាននូវការកាន់កាប់មួយប្រកបដោយសុវត្ថិភាព។

# អនុសាសន៍

តាមការចុះសិក្សាស្រាវជ្រាវបានស្វែងយល់ថា ចំពោះដំណើរការនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅខេត្តព្រៃវែងនេះ បើទោះបីជាទទួលបានជោគជ័យច្រើនក៏ដោយ ក៏ក្នុងដំណើរការនេះនៅតែមានកើតឡើងនៅចំណុចខ្វះខាតមួយចំនួន ដែលគួរគប្បីលើកយកមកត្រិះរិះពិចារណា និងចាត់វិធានការបំពេញបន្ថែម។

ចំណុចខ្វះខាត ដែលគួរគប្បីលើកយកមកត្រិះរិះពិចារណា និងចាត់វិធានការបំពេញបន្ថែមត្រូវមានដូចជា ការបង្កើនការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់មានការយល់ដឹងពីផលប្រយោជន៍នៃការធ្វើប័ណ្ណកម្មសិទ្ធិនិង ត្រូវរៀបចំឲ្យមានការពិភាក្សាលម្អិតបន្ថែមទៀត ទៅលើដំណើរការបំពេញទម្រង់បែបបទ នៃការប្រមូលទិន្នន័យក្បាលដីសម្រាប់មន្ត្រីវិនិច្ឆ័យ ដែលជាផ្នែកមួយដ៏សំខាន់នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

រីឯកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីគួរតែមាន កម្មវិធីសម្រាប់ចុះជួយពង្រឹងដល់មន្ត្រី និងធ្វើការបំពាក់បំប៉នបន្ថែមលើច្បាប់ និង បច្ចេកទេស។ ចំណែកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់វិញគួរណាស់តែកំណត់តម្លៃពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិអចលនវត្ថុ ប្រកបទៅដោយភាពច្បាស់លាស់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងមានការផ្សព្វផ្សាយជាសាធារណៈឲ្យប្រជាពលរដ្ឋបានដឹង នាំគ្នាអនុវត្តឲ្យមានប្រសិទ្ធភាព ដើម្បីធានាបាននូវការរកចំណូលសម្រាប់ថវិកាជាតិ។

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់សំណើដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីតម្លៃសេវាចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ, លេខ០៥៩សហវ, ២៥វិច្ឆិកា២០០៣។

សារាចរណែនាំអនុវត្តន៍នីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ, លេខ០០១ដសន/សជ, ១៩ សីហា ២០០២។

សេចក្តីសម្រេចស្តីពីការកំណត់តំបន់សម្រាប់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ, លេខ០០៤/១២សសរ, ១៣ មករា ២០១២ ។

សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការរដ្ឋបាលក្នុងតំបន់ធ្វើការវិនិច្ឆ័យសម្រាប់នៅនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី, លេខ០០៧/១២សសរ, ១៨ មករា ២០១២។

គង់ អ៊ន់, *កំណត់ហេតុស្តីពីកិច្ចប្រជុំពិភាក្សាកំណត់ព្រំប្រទល់រដ្ឋបាលរវាងឃុំស្មោងជើង និងឃុំដទៃទៀត*, ២៤ កុម្ភៈ ២០១២។

សំណើបើកវគ្គបណ្តុះបណ្តាលគណៈកម្មការរដ្ឋបាលដល់ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋាន និង ភូមិសាស្ត្រ និង ជានាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី, លេខ៨៤/១២, ១២ មីនា ២០១២។

កែវសេន,*របាយការណ៍បូកសរុបការអនុវត្តន៍នីតិវិធីនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ*, លេខ៣០៩ (ព្រៃវែង៖ ១៤ មិថុនា ២០១៣)។

សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ, លេខ២៤៦/១៣សជណ, ២៥ មេសា ២០១៣។

សេចក្តីជូនដំណឹងស្តីពីការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនិងមោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, លេខ៤៥០/១៣ សជណ, ១៤ មិថុនា ២០១៣។

សេចក្តីស្នើសុំឲ្យCPMOតាមរយៈឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដីនិង ភូមិសាស្ត្រ និង ជានាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី, លេខ០១៦/១៣PPMO/PV, ១៤មិថុនា ២០១៣។

សំណើសុំជួយផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និង មោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ តាមទូរទស្សន៍ជាតិកម្ពុជា, លេខ១៨៣/១៣លស,១៤ មិថុនា ២០១៣។

ស៊ាន យុទ្ធី, លិខិតជូនលោកនាយកចាត់ការគម្រោងខេត្តស្តីពីលទ្ធផលនៃការចុះពិនិត្យគុណភាពក្បាលដី, ២៩ មេសា ២០១៣។

## សៀវភៅ និង ឯកសារផ្សេងៗ

Matthew Rendall, Josee Tremblay និង Patricia. *ច្បាប់ភូមិបាលកម្ពុជា និងសៀវភៅស្រាវជ្រាវ* (ភ្នំពេញ៖ East-West management institute, 2005)។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ, *ឯកសារបណ្តុះបណ្តាលការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ.* (ហ្វាំងឡង់ និង កាណាដា៖ មីនា ឆ្នាំ២០០៨)។

អ៊ុន សក្កដា, សៀវភៅនីតិនគរូបនីយវិទ្យា (ភ្នំពេញ, ២០១៣)។

## បទសម្ភាស

បទសម្ភាសជាមួយនឹងអនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសុរិយោដីខេត្តព្រៃវែង (ទទួល បន្ទុកការងារសុរិយោដី និង ភូមិសាស្ត្រខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន ( ២០ ឧសភា ២០១៤)។

បទសម្ភាសជាមួយនឹងមេភូមិពោន ស្រុកកំចាយមារខេត្តព្រៃវែង, ២៦ មិថុនា ២០១៤ ។

បទសម្ភាសជាមួយនឹងមន្ត្រីបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដី, ៣ កក្កដា ២០១៤។

បទសម្ភាសជាមួយនឹងមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តព្រៃវែង (ទទួលបន្ទុកគ្រប់គ្រងតំបន់វិនិច្ឆ័យ ស្រុកកំចាយមារ ខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន (២៦ ឧសភា ២០១៤)។

បទសម្ភាសន៍ប្រជាពលរដ្ឋ ស្រុកកំចាយមារ ខេត្តព្រៃវែង, ២៦ មិថុនា ២០១៤។

បទសម្ភាសជាមួយនឹងមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សុរិយោដីខេត្តព្រៃវែង (ទទួលបន្ទុកវាស់វែងដីធ្លីនៅឃុំស្មោងជើង ខេត្តព្រៃវែង), បទសម្ភាសផ្ទាល់ខ្លួន (៣ កក្កដា២០១៤)។